# របាយការណ៍សង្ខេប
# ស្តីពី
# សកម្មភាពការងារសំខាន់ៗ
# ប្រចាំឆមាសទី១ ឆ្នាំ២០២៤
# របស់
# ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## អគ្គលេខាធិការដ្ឋាន

# សេចក្ដីផ្ដើម

ក្រោមឧត្តមមគ្គុទេសក៍ និងចក្ខុវិស័យដឹកនាំប្រាកដនិយមប្រកបដោយគតិបណ្ឌិតរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, រាជរដ្ឋាភិបាលបានអនុវត្តប្រកបដោយជោគជ័យជាផ្លែផ្កា នូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នីតិកាលទី៧ នៃរដ្ឋសភា ដើម្បីពង្រឹងនិងពង្រីកសមិទ្ធផលនានា ដែលសម្រេចបានឱ្យកាន់តែមានការរីកចម្រើនលើគ្រប់វិស័យបន្ថែមទៀត។ ក្នុងរយៈពេលជាងពីរទសវត្សន៍ចុងក្រោយនេះ កម្ពុជាបានរក្សានូវកំណើនសេដ្ឋកិច្ចខ្ពស់ និងជាប្រទេសដែលសម្រេចបាននូវជោគជ័យដ៏ល្អប្រសើរក្នុងការកែទម្រង់ស៊ីជម្រៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការលើកកម្ពស់ជីវភាពប្រជាជនឱ្យកាន់តែប្រសើរឡើង តាមរយៈការបែងចែកកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន, ការបង្កើតការងារថ្មីៗបន្ថែមជូនប្រជាជន, ការធានាបាននូវសមធម៌សង្គម, ការផ្ទេរអំណាច និងស្វ័យភាពកាន់តែច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ ដែលជាកត្តាធ្វើឱ្យគំលាតជីវភាពរវាងអ្នកមាននិងអ្នកក្រកាន់តែខិតជិតគ្នាគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។ ទោះបីជាក្នុងឆមាសទី១ ឆ្នាំ២០២៤ នេះ សេដ្ឋកិច្ចរបស់ពិភពលោកទាំងមូលរួមទាំងព្រះរាជា-ណាចក្រកម្ពុជាផងដែរ បានបន្តរងផលប៉ះពាល់នៃសង្គ្រាម មិនប្រាកដប្រជាដែលបង្ករដោយសង្គ្រាមរវាងប្រទេសរូស្សី និងប្រទេសអ៊ុយ-ក្រែន, និងសង្គ្រាមរវាងប្រទេសអ៊ីស្រាអែល និងប្រទេសប៉ាឡេស្ទីន, រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួង-ស្ថាប័នពាក់ព័ន្ធជាសេនា-ធិការ បានខិតខំដោយយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពក្នុងការប្រយុទ្ធប្រឆាំងទប់ស្កាត់ និងគ្រប់គ្រងស្ថានភាពសង្គមសេដ្ឋកិច្ចដែលជះឥទ្ធិពលជាអវិជ្ជមានដោយសារសង្គ្រាមរវាងប្រទេសរូស្ស៊ី និងប្រទេសអ៊ុយក្រែន ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីជួយសម្រួល និងកាត់បន្ថយផលប៉ះពាល់លើវិស័យសំខាន់ៗមួយចំនួនដែលជាជន្ទល់សេដ្ឋកិច្ច ក្នុងគោលដៅរក្សាស្ថិរភាពសេដ្ឋកិច្ច និងធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ចកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០២៤ នេះ អាចសម្រេចបាននូវកំណើតមួយសមរម្យ ដែលជាស្ពានឈានទៅសម្រេចបាននូវគោលដៅសេដ្ឋកិច្ចជាតិឆ្នាំ២០៥០ ដែលរាជរដ្ឋាភិបាលបានកំណត់ចក្ខុវិស័យដាក់លាក់រួចជាស្រេច។

តាមរយៈនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបន្តធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃយ៉ាងច្បាស់លាស់លើការអនុវត្តមុខងារភារកិច្ចរបស់ក្រសួង-ស្ថាប័ននីមួយៗ សំដៅបង្កើន និងរក្សាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តកិច្ចការងារ ដោយបានតម្រូវឱ្យមានរបបរាយការណ៍ជាផ្លូវការអំពីវឌ្ឍនភាព នៃការអនុវត្តការងាររបស់អង្គភាពខ្លួន ជា**ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ** ដើម្បីរាជរដ្ឋាភិបាលមានមូលដ្ឋានពិនិត្យបូកសរុប តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារ នៃការអនុវត្តគោលបំណងគោលនយោបាយរបស់គ្រប់ក្រសួង-ស្ថាប័ន ដែលរាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព និងផលិតភាពខ្ពស់ ព្រមទាំងអាចទទួលបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ចាត់វិធានការដោះស្រាយ និងចាត់ចែងរៀបចំផែនការជាបន្តបានទាន់ពេលវេលា។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏មិនខុសគ្នាពីក្រសួង-ស្ថាប័នដទៃ គឺត្រូវមានកាតព្វកិច្ចរាយការណ៍ពីវឌ្ឍនភាព នៃការអនុវត្តគោលបំណងគោលនយោបាយចំនួនពីររបស់ខ្លួនដែលរាជរដ្ឋាភិបាលបានប្រគល់ជូន គឺ១. ការពង្រឹងសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ និង២. ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងកម្មវិធីរបស់ក្រសួងចំនួនប្រាំជូនដល់រាជរដ្ឋាភិបាលជាប្រចាំផងដែរ និងតែងតែបានរៀបចំរបាយការណ៍សកម្មភាពការងាររបស់ខ្លួន និងបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីយ៉ាងទៀងទាត់ជាប្រចាំ។

របាយការណ៍សកម្មភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនាពេលនេះត្រូវបានរៀបចំឡើង តាមរយៈការប្រមូលធាតុចូលពីរបាយការណ៍សកម្មភាពការងារ នៃគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាតួអង្គ អនុវត្តផ្ទាល់ យកមកពិនិត្យចងក្រង និងធ្វើអាទិភាវូបនីយកម្មសម្រួចសកម្មភាពធំៗ ដោយទាញយកចំណុចសំខាន់ៗបញ្ចូលទៅក្នុងកម្មវិធីនិងអនុកម្មវិធី ជាសមត្ថកិច្ចរបស់អង្គភាពជំនាញស្របតាមគោលបំណងគោលនយោបាយរបស់ក្រសួង និងបង្ហាញអំពីសមិទ្ធផលការងារសំខាន់ៗ ដែលអង្គភាពនីមួយៗបានខិតខំសម្រេចបានក្នុងត្រីមាសទី១ ឆ្នាំ២០២៤នេះ ព្រមទាំងរំលេចអំពីសូចនាករដែលមិនទាន់សម្រេចបានដើម្បីជាមូលដ្ឋានពិនិត្យ តាមដាន វាយតម្លៃ និងពង្រឹងការអនុវត្តបន្តឱ្យកាន់តែមានគុណភាពបន្ថែមទៀត។ ខ្លឹមសារក្នុងផ្នែកនីមួយៗនៃរបាយការណ៍នេះ ត្រូវបានរៀបចំពណ៌នាជាសមិទ្ធផល និងសកម្មភាពគន្លឹះៗ

ដែលអង្គភាពសម្រេចបាន ទាំងការងារប្រចាំថ្ងៃ និងការងារកែទម្រង់ ក្នុងគោលដៅធ្វើយ៉ាងណាប្រមូលផ្តុំព័ត៌មានឱ្យបានពេញលេញគ្រប់ជ្រុងជ្រោយ និងមានសារប្រយោជន៍ពីគ្រប់ផ្នែកគាំទ្រទាំងអស់របស់ក្រសួងសំដៅត្រួតពិនិត្យតាមដាន និងជំរុញការបំពេញមុខងារជាសេនាធិការរបស់រាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំនិងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់។

## ១. ការគ្រប់គ្រងសេដ្ឋកិច្ច និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

ស្របតាមផែនការយុទ្ធសាស្ត្រថវិកា២០២២-២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គោលបំណងគោលនយោបាយទី១ "ការគ្រប់គ្រងសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ"មានកម្មវិធីចំនួន២ ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីឈានទៅសម្រេចគោលបំណងគោល-នយោបាយនេះ។

### ១.១. ការគ្រប់គ្រងសេដ្ឋកិច្ច

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានគោលនយោបាយ និងអគ្គលេខាធិការដ្ឋានគណៈកម្មការផលិតភាពសេដ្ឋ-កិច្ចកម្ពុជា។ អគ្គនាយកដ្ឋានគោលនយោបាយមានមុខងារសំខាន់ៗ ក្នុងការរៀបចំ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, តាមដាន និងវាយតម្លៃនិន្នាការសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក ក្នុងកម្រិតវិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចូលរួមចំណែកក្នុងការងារពាក់ព័ន្ធដល់ការរៀបចំគោលនយោបាយ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុក្រៅប្រទេស និងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ ក្នុងតំបន់ និងពិភពលោក[1]។ រីឯអគ្គលេខាធិការដ្ឋានគណៈកម្ម-ការផលិតភាពសេដ្ឋកិច្ចកម្ពុជាផ្តោតលើកិច្ចការរដ្ឋបាលនិងការងារបច្ចេកទេសសិក្សាស្រាវជ្រាវ សម្រាប់គាំទ្រកិច្ចដំណើការរបស់គណៈកម្មការផលិតភាពសេដ្ឋកិច្ចកម្ពុជា។ ជាលទ្ធផលប្រចាំឆមាសទី១ ឆ្នាំ២០២៤ អង្គភាពទាំងពីរបានអនុវត្ត និងទទួលបានវឌ្ឍនភាពដូចមានក្នុងរបាយការណ៍ខាងក្រោម៖

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីអនុវត្តការងារសម្រាប់គ្រប់មុខសញ្ញាកិច្ចលទ្ធកម្មសាធារណៈតាម FMIS សម្រាប់ក្របខណ្ឌក្រសួង កសហវ និងក្រសួងបរិស្ថាន
- សម្រាប់ឆមាសទី១ ឆ្នាំ២០២៤នេះ, អគ្គលេខាធិការដ្ឋាន គ.ជ.ផ.ក. បានអនុវត្តគម្រោងសិក្សាស្រាវជ្រាវចំនួន ៣ រួមមាន៖
  - ការគ្រោង និងរៀបចំវិធីសាស្ត្រនៃ ក្របខណ្ឌតាមដាន និងវាយតម្លៃលើផលិតភាពសេដ្ឋកិច្ចកម្ពុជា
  - អភិវឌ្ឍប្រព័ន្ធវាស់វែងផលិតភាពសេដ្ឋកិច្ចជាតិ
  - ការគ្រោង និងរៀបចំអភិក្រមនៃក្របខណ្ឌតាមដាន និងវាយតម្លៃលើផលិតភាពសេដ្ឋកិច្ចកម្ពុជា
- ការតាមដាន និងវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥ ÷ ការអនុ-វត្តកម្មវិធីអភិវឌ្ឍមូលធនមនុស្សផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ផ.ក.៖
  - បានសិក្សា និងវិភាគអំពីយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីបន្ស៊ីការរៀបចំ និងអនុវត្តកម្មវិធីគម្រោង និងផែនការសកម្មភាពនានារបស់ អ.គ.ជ.ផ.ក.
  - បានអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពក្រុមការងារ អ.គ.ជ.ផ.ក. អំពីចំណេះដឹងនិងជំនាញក្នុងការប្រើប្រាស់ទិន្នន័យ រួមមាន៖ ក្របខណ្ឌ ការតាមដាន និងការវាយតម្លៃ, ប្រព័ន្ធតាមដាន និងវាយតម្លៃរបស់ UNISDR, ប្រភពទិន្នន័យ និងម៉ូដែលសម្រាប់ព្យាករណ៍, METADATA, Framework and Template, Type of Variable
- បានសិក្សាស្វែងយល់លើឯកសារ General Guideline on Public Investment Management
- របាយការណ៍និងកម្រងស្ថិតិ គិតត្រឹមខែឧសភា ឆ្នាំ២០២៤៖
  - ប្រតិបត្តិការហិរញ្ញវត្ថុ (TOFE)
  - ហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)សម្រាប់ថ្នាក់ក្រោមជាតិទាំង០៣កម្រិត
- របាយការណ៍ និងកម្រងទិន្នន័យ៖
  - តាមដាននិន្នាការសេដ្ឋកិច្ចសង្គម
  - រូបិយវត្ថុ, ពាណិជ្ជកម្ម
  - និន្នាការសេដ្ឋកិច្ច-សង្គម

---

[1] មាត្រា ១២ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




របាយការណ៍និន្នាការសេដ្ឋកិច្ច-សង្គម
ប្រចាំខែមិថុនា ឆ្នាំ២០២៤

- ➢ បានរៀបចំកម្រងទិន្នន័យស្ថិតិគិតត្រឹមខែឧសភា ឆ្នាំ២០២៤៖
- • ទំហំពាណិជ្ជកម្មអន្តរជាតិ, ឧស្សាហកម្ម
- • រ៉ែថាមពល, វិនិយោគ, សំណង់, ទេសចរណ៍, កសិកម្ម
- • អត្រាប្តូរប្រាក់ជាតិ និងអន្តរជាតិធៀបនឹងប្រាក់ដុល្លារអាម៉េរិក
- ➢ បានរៀបចំរបាយការណ៍ គិតត្រឹមខែឧសភា ឆ្នាំ២០២៤៖
- • វិភាគអតិផរណា
- • ស្ថានភាពពាណិជ្ជកម្ម, ស្ថិតិសេដ្ឋកិច្ច
- • សកម្មភាពសេដ្ឋកិច្ចតាមវិស័យ។

## ១.២. ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារ ,អគ្គលេខាធិការដ្ឋានល្បែងពាណិជ្ជកម្មកម្ពុជា, និយ័តករធានារ៉ាប់រងកម្ពុជា, និយ័តករមូលបត្រកម្ពុជា, និយ័តករបរធនបាលកិច្ច,និយ័តករអាជីវកម្មអចលនទ្រព្យ និងបញ្ចាំ អង្គភាពសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលទើបបង្កើត និងបំបែកចេញពីអគ្គនាយកឧស្សាហកម្មហិរញ្ញវត្ថុ និយ័តករគណនេយ្យ និងសវនកម្ម លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ អង្គភាពដែលទើបបំបែកពីឧស្សាហកម្មហិរញ្ញវត្ថុ មានមុខងារក្នុងការគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ អាជីវកម្មភ្នាល់គ្រប់ប្រភេទ អាជីវកម្មអចលនទ្រព្យនិងចូលរួមប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ និយ័តករគណនេយ្យ និងសវនកម្ម បំពេញបេសកកម្មគ្រប់គ្រងអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម។ សម្រាប់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមវិញ បំពេញមុខងារជាសេនាធិការគោលនយោបាយ និងបច្ចេកទេសរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។ ជាលទ្ធផល អង្គភាពទាំងអស់ខាងលើបានអនុវត្តនិងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

### ១.២.១. វិស័យបរធនបាលកិច្ច

- ➢ បានពិនិត្យ និងផ្តល់ការចុះបញ្ជីបរធនបាលកិច្ចចំនួន ១៣៣ ករណី
- ➢ បានពិនិត្យ និងផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត/ ការចុះបញ្ជីដល់ /ក្រុមហ៊ុន បរធនបាល/ប្រតិបត្តិករបរធនបាល/បរធនបាលរូបវន្តបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិនិងបុគ្គលពាក់ព័ន្ធផ្សេងៗទៀតចំនួន ៨១ករណី
- ➢ បានពិនិត្យ និងផ្តល់យោបល់លើការផ្លាស់ប្តូរព័ត៌មានក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ចរបស់ក្រុមហ៊ុន ចំនួន ២៩ ករណី
- ➢ ពិនិត្យ និងតាមដានលើការបង់វិភាគទាន និងសោហ៊ុយវិញ្ញាបនបត្រ ចុះបញ្ជីប្រចាំឆ្នាំ ១៨២ ករណី
- ➢ ពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍និយោជិតចំនួន ១៧០ ករណី
- ➢ បានចុះត្រួតពិនិត្យដល់ទីកន្លែងប្រតិបត្តិករបរធនបាលកិច្ច ចំនួន ៩ លើក
- ➢ បានរៀបចំផែនការអភិវឌ្ឍន៍ស្ថាប័ន បច្ចុប្បន្នកម្មសម្រាប់រយៈពេល ១០ ឆ្នាំ (២០២១-២០៣០) របស់និយ័តករបរធនបាលកិច្ច ព្រមទាំងទទួលបានការអនុម័តពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្រ្តី
- ➢ បានរៀបចំរបាយការណ៍វាយតម្លៃពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ចពាណិជ្ជកម្ម (សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសាច់ប្រាក់សម្រាប់ទូទាត់ថ្លៃទិញ-លក់ អចលនវត្ថុ) ចំនួន ២ ករណី
- ➢ បានរៀបចំរបាយការណ៍វាយតម្លៃពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ចពាណិជ្ជកម្មទាំង ៨ ករណី

- បានចុះអធិការកិច្ចដើម្បីជំរុញការអនុវត្តច្បាប់លើសកម្មភាពសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវលើការរៀបចំសៀវភៅណែនាំស្តីពីការធ្វើអធិការកិច្ចបរធនបាលកិច្ច
- បានសិក្សាស្រាវជ្រាវអំពីសញ្ញាណទូទៅ នៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដើម្បីទទួលបានធាតុចូលលម្អិតសំខាន់ៗក្នុងការរៀបចំឯកសារទស្សនាទានស្តីពីយន្តការ បែបបទ និងនីតិវិធីនៃការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច
- បានសិក្សាស្រាវជ្រាវអំពីក្រុមប្រឹក្សាដោះស្រាយវិវាទក្នុងវិស័យប្រហាក់ប្រហែលដើម្បីបានជាធាតុចូលសម្រាប់ការរៀបចំឯកសារទស្សនាទានស្តីពីក្រុមប្រឹក្សាដោះស្រាយវិវាទក្នុងវិស័យបរ-ធនបាលកិច្ច។


Weekly Article
What is a Pet Trust?

Pet Trust is a legal agreement that provides care and maintenance of pets in the event of an owner's disability or death.

Pet Trust is created to ensure that their pets can continue to receive care and maintenance in case the owner becomes incapacitated to continue to take care of them or passed away. The person who created the trust is called trustor and the person who manages the fund is called trustee. The trust can be effective either during the owner's lifetime or after death. Typically, the trustee will be the holder of assets (i.e., Cash) in trust for the trustor's pet or the pet and will make regular payments to caregivers as assigned in the trust. The trustor can outline about how the pet is taken care of, type of food, schedule for health screening, veterinarian that will be responsible for their pet's health and so on.



អត្ថបទប្រចាំសប្តាហ៍

តើអ្វីទៅជាបរធនបាលកិច្ចសត្វចិញ្ចឹម?

### ១.២.២.វិស័យអចលនទ្រព្យ និងបញ្ចាំ

- ការផ្តល់/បន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអគារសហកម្មសិទ្ធិ និងការផ្លាស់ប្តូរផ្សេងៗ៖
    - ផ្តល់អាជ្ញាបណ្ណថ្មីចំនួន ២៨ គម្រោង និងលិខិតអនុញ្ញាតជាគោលការណ៍ចំនួន ០៣ គម្រោង
    - បន្តសុពលភាពអាជ្ញាបណ្ណចំនួន ០៨ គម្រោង និងបន្តសុពលភាពលិខិត អនុញ្ញាតជាគោលការណ៍ចំនួន ០៥ គម្រោង
    - បន្ថែមលេខគណនីអភិវឌ្ឍអចលនវត្ថុចំនួន ០៤ គម្រោង
    - ប្តូរលេខគណនីអភិវឌ្ឍអចលនវត្ថុចំនួន ០១ គម្រោង
    - បានកែប្រែសមាសភាពភាគហ៊ុនិកចំនួន ០២ គម្រោង
    - ផ្លាស់ប្តូរធនាគារដាក់ប្រាក់តម្កល់ចំនួន ០១ គម្រោង
    - អនុញ្ញាតឱ្យដកប្រាក់តម្កល់ជានាអាជីវកម្ម ចំនួន១៤ គម្រោង
- បានធ្វើការផ្តល់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍដីឡូត៍៖
    - ផ្តល់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍដីឡូត៍ថ្មី ចំនួន ០៦ ក្រុមហ៊ុន (០៧ គម្រោង)
    - បានបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍន៍ដីឡូត៍ចំនួន ០១ក្រុមហ៊ុន (០១ គម្រោង)
    - ចុះត្រួតពិនិត្យទីតាំងអាជីវកម្មអភិវឌ្ឍន៍ដីឡូត៍ចំនួន ០៣ក្រុមហ៊ុន (០៣គម្រោង)



ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រត្តិបតិការលើការលើកកម្ពស់ការយល់ដឹងការកសាងសមត្ថភាព និងផ្លាស់ប្តូរជំនួយបច្ចេកទេសក្នុងក្របខណ្ឌវិស័យអចលនវត្ថុ

- ការផ្តល់/បន្តសុពលភាពអាជ្ញាបណ្ណនិងវិញ្ញាបនបត្រ-វិជ្ជាជីវៈក្រុមហ៊ុន សេវាកម្មវាយតម្លៃ និងអចលនវត្ថុ និងការផ្លាស់ប្តូរ ផ្សេងៗ៖
    - ផ្តល់អាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈជូនក្រុមហ៊ុនថ្មីចំនួន ០៨ ក្រុមហ៊ុន
    - បន្តសុពលភាពអាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈជូនក្រុមហ៊ុនចំនួន ១០៧ ក្រុមហ៊ុន




ចំណេះដឹងពីធានារ៉ាប់រង
UNDERSTANDING INSURANCE

- អនុញ្ញាតឱ្យបន្ថែម និង/ឬផ្លាស់ប្តូរ និង/ឬបញ្ឈប់អាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈជូនក្រុមហ៊ុនចំនួន ២៧ ក្រុមហ៊ុន
- អនុញ្ញាតឱ្យផ្លាស់ប្តូរភាគហ៊ុនិក និង/ឬសមាជិកក្រុមប្រឹក្សាភិបាល, ផ្លាស់ប្តូរទីតាំងជូនក្រុមហ៊ុនចំនួន ២៤ ក្រុមហ៊ុន

➢ ការផ្តល់/បន្តអាជ្ញាបណ្ណអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន៖

- ផ្តល់អាជ្ញាបណ្ណអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទានចំនួន ១១ ក្រុមហ៊ុន/សហគ្រាស
- ផ្តល់អាជ្ញាបណ្ណថ្មីតាមថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (CAMDX) ចំនួន ១២ ក្រុមហ៊ុន/សហគ្រាស
- បន្តសុពលភាពអាជ្ញាបណ្ណចំនួន ១៣៩ ក្រុមហ៊ុន/សហគ្រាស
- បន្តសុពលភាពតាមថ្នាលប្រព័ន្ធបច្ចេកវិទ្យា (CAMDX) ចំនួន ២២ ក្រុមហ៊ុន/ សហគ្រាស
- បានចេញលិខិតគោលការណ៍ឯកភាពដកប្រាក់តម្កល់ និងបិទសកម្មភាពអាជីវកម្មចំនួន ១៧ ក្រុមហ៊ុន/សហគ្រាស និងសាខាចំនួន ០៥

➢ ការចុះត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអគារសហកម្មសិទ្ធិ៖
- ចុះត្រួតពិនិត្យគម្រោងមានច្បាប់អនុញ្ញាតចំនួន ០៨ គម្រោង
- ចុះស្រាវជ្រាវក្រុមហ៊ុនធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអគារ សហកម្មសិទ្ធិគ្មានច្បាប់ចំនួន ៤១ គម្រោង

➢ ការចុះត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍដីឡូត៍៖
- ចុះត្រួតពិនិត្យគម្រោងមានច្បាប់អនុញ្ញាតចំនួន ០១គម្រោង
- ចុះស្រាវជ្រាវគម្រោងគ្មានច្បាប់ចំនួន ១៦គម្រោង

➢ ការចុះត្រួតពិនិត្យអាជីវកម្មសេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ៖
- ចុះត្រួតពិនិត្យក្រុមហ៊ុនផ្តល់សេវាកម្មវាយតម្លៃ និងអចលនវត្ថុមានច្បាប់ ចំនួន ១២ ក្រុមហ៊ុន
- ចុះស្រាវជ្រាវក្រុមហ៊ុនគ្មានច្បាប់ចំនួន ២៦ ក្រុមហ៊ុន

➢ ការចុះត្រួតពិនិត្យអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន៖
- ចុះត្រួតពិនិត្យក្រុមហ៊ុន/សហគ្រាសមានច្បាប់ចំនួន ៤៥ ក្រុមហ៊ុន/ សហគ្រាស
- ចុះស្រាវជ្រាវក្រុមហ៊ុន/សហគ្រាសគ្មានច្បាប់ចំនួន ១៤ ក្រុមហ៊ុន/ សហគ្រាស។

### ១.២.៣. វិស័យធានារ៉ាប់រងនៅកម្ពុជា

➢ បានរៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែធ្នូ គ.ស.២០២៣ ដល់ខែឧសភា គ.ស.២០២៤

➢ បានសម្រេចអនុញ្ញាតផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការី៖
- ធានារ៉ាប់រង ជាក្រុមហ៊ុនជើងសាធានារ៉ាប់រងអាយុជីវិតរបស់ក្រុមហ៊ុនជើងសាធានារ៉ាប់រងចំនួន ៣
- ធានារ៉ាប់រង ជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងចំនួន ១
- ធានារ៉ាប់រង ជាក្រុមហ៊ុនជើងសាធានារ៉ាប់រងទូទៅចំនួន ១

➢ បានសម្រេចអនុញ្ញាតផ្តល់អាជ្ញាបណ្ណអាជីវកម្ម៖
- សេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងចំនួន ១
- សេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងចំនួន ១
- របស់ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងចំនួន ១

- បានសម្រេចអនុញ្ញាតបន្តសុពលភាពអាជ្ញាបណ្ណ និងវិញ្ញាបនបត្រ៖
    - ជានាវ៉ាប់រងរបស់ក្រុមហ៊ុនជានាវ៉ាប់រងទូទៅចំនួន ១
    - អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនជានាវ៉ាប់រងទូទៅចំនួន ១
    - អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន ៣
    - អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងចំនួន ៩
    - អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនជើងសាធានារ៉ាប់រងទូទៅចំនួន ១
    - អាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងចំនួន ១
- បានសម្រេចអនុញ្ញាតផ្ទេរភាគហ៊ុនរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន ១
- បានសម្រេចអនុញ្ញាតជាគោលការណ៍លើការផ្ទេរភាគហ៊ុនរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន ១
- បានសម្រេចអនុញ្ញាតកែប្រែលក្ខខណ្ឌនៃលក្ខន្តិកៈក្រុមហ៊ុនរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន ២និងក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន ១
- បានសម្រេចអនុញ្ញាតផ្លាស់ប្តូរទីតាំងរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន ១។

### ១.២.៤. វិស័យគ្រប់គ្រងល្បែងនៅកម្ពុជា

- គ្រប់គ្រង និងប្រមូលចំណូលពាក់ព័ន្ធនឹងវិស័យល្បែងពាណិជ្ជកម្ម៖
    - បានផ្តល់អាជ្ញាបណ្ណដល់ប្រតិបត្តិករកាស៊ីណូសរុបចំនួន១៨៥ (មួយរយប៉ែតសិបប្រាំ)
    - ប្រតិបត្តិករកាស៊ីណូដែលបើកដំណើរការអាជីវកម្ម និងប្រកាសចំណូលកាតព្វកិច្ចពីល្បែងប្រចាំឆ្នាំ២០២៣ និងមានកាតព្វកិច្ចផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំ២០២៣ និងឯកសារតម្រូវពាក់ព័ន្ធចំនួន ១៥៧ ក្រុមហ៊ុន
    - ប្រតិបត្តិករល្បែងផ្សងសំណាងដែលត្រូវរងសវនកម្មប្រចាំឆ្នាំ២០២៣ សរុបមានចំនួន ១៩ក្រុមហ៊ុន
- គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពកាស៊ីណូ និងល្បែងផ្សងសំណាង៖
    - បានចេញលិខិតទទួលស្គាល់បុគ្គលិកពិសេសកាស៊ីណូចំនួន ១៩កាស៊ីណូ សរុបចំនួន ៨៩៧រូប
    - បានចេញលិខិតលុបឈ្មោះបុគ្គលិកពិសេសកាស៊ីណូចំនួន ១៦កាស៊ីណូ សរុបចំនួន ១៤១រូប
    - បានប្រែក្លាយអាជ្ញាបណ្ណបណ្តោះអាសន្នទៅជាអាជ្ញាបណ្ណពេញលេញចំនួន ៨កាស៊ីណូ
    - បានចេញសេចក្តីសម្រេចស្តីពីការព្យួរអាជ្ញាបណ្ណកាស៊ីណូចំនួន ៤កាស៊ីណូ
    - បានចេញលិខិតឱ្យកាស៊ីណូចំនួន ៤ ចុះហត្ថលេខាលើសៀវភៅបន្ទុកស្តីពីលក្ខខណ្ឌនៃការបន្តសុពលភាពអាជ្ញា-បណ្ណកាស៊ីណូក្នុងឆ្នាំ២០២២ និងបំពេញឯកសារតម្រូវសម្រាប់ស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ
    - បានចេញសេចក្តីសម្រេចស្តីពីការព្យួរ និងការដកហូតអាជ្ញាបណ្ណអាជ្ញាបណ្ណល្បែងផ្សងសំណាងចំនួន ២ក្រុមហ៊ុន
    - ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតចុះបញ្ជីប្រភេទល្បែង វិធានល្បង ឧបករណ៍និង/ឬកម្មវិធីល្បែងសម្រាប់កាស៊ីណូមានចំនួន១៤២ក្រុមហ៊ុន ស្មើ៧៧.១៧%
    - ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតចុះបញ្ជីប្រភេទល្បែង និងឧបករណ៍ល្បែងសម្រាប់ល្បែងផ្សងសំណាងមានចំនួន ១៧ក្រុមហ៊ុន ស្មើ ៨០.៩៥%។

### ១.២.៥ វិស័យមូលបត្រកម្ពុជា

- បានពិនិត្យ និងផ្តល់យោបល់ពាក់ព័ន្ធការតាមដានកាតព្វកិច្ច៖
    - របស់ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃចំនួន ៥ ករណី
    - របស់ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលចំនួន ៤ ករណី
    - របស់ភ្នាក់ងារវាយតម្លៃលទ្ធភាពសងចំនួន ១ ករណី
- បានបញ្ជ្រាបការយល់ដឹង និងជំរុញការបោះផ្សាយមូលបត្រចំនួន ១ ករណី
- បានពិនិត្យ និងផ្តល់យោបល់លើការអនុវត្តកាតព្វកិច្ចអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រស្របតាមប្រកាសចំនួន ១៧ ករណី
- បានតាមដាន និងត្រួតពិនិត្យលើការអនុវត្តកាតព្វកិច្ច៖

- ការផ្តល់របាយការណ៍សាមាយិក ចំនួន ៤២ ករណី
- ការបង្ហាញព័ត៌មានទាន់ពេល ចំនួន ១១២ ករណី
- ការបង្ហាញព័ត៌មានពិសេស ចំនួន ១ ករណី
- ការបង្ហាញព័ត៌មានតាមការស្ម័គ្រចិត្ត ចំនួន ១៩ ករណី
- ការបង្ហាញព័ត៌មានតាមការស្នើសុំ ចំនួន ១០ ករណី
- ការស្នើសុំបោះផ្សាយលក់មូលបត្រចំនួន ១៣ ករណី
- ការស្នើសុំបោះផ្សាយលក់មូលនិធិចំនួន ៤ ករណី។

### ១.២.៦. ការងារគាំពារសង្គម

- ➢ បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាង "គោលការណ៍ណែនាំ ស្តីពីការវាយតម្លៃនីតិវិធី សម្រាប់ការបើកផ្តល់តាវកាលិកជូនសមាជិក"
- ➢ បានសម្រេចបាននូវអនុក្រឹត្យលេខ៤០ អនក្រ. បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការអនុវត្តកម្មវិធីស្តារជីវភាពឡើងវិញ សម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនទៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង នៃស្រុកអង្គរធំ នៃខេត្តសៀមរាប


សប្តាហ៍គាំពារសង្គមកម្ពុជា
បន្តកសាងប្រព័ន្ធគាំពារសង្គមដើម្បីចីរភាព និងភាពធន់

- ➢ បានរៀបចំរបាយការណ៍ស្តីពី ករណីប្រជាជនដែលបានផ្លាស់ប្តូរលំនៅដ្ឋានមកក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែងក្នុងការទទួលបានអត្ថប្រយោជន៍ជំនួយសង្គម ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៤ គោរពជូន សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី
- ➢ បានរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការក្រុមប្រឹក្សាជាតិគាំពារសង្គមស្តីពីផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤
- ➢ បានរៀបចំរបាយការណ៍វឌ្ឍនភាពការងារពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ របស់និយ័តករសន្តិសុខសង្គម ជូន អ.ស.ហ ចំនួន ២ លើក។

### ១.២.៧. ការងារគណនេយ្យ និងសវនកម្ម

- ➢ ពិនិត្យ និងកែសម្រួលសេចក្តីព្រាងស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១ ស្តីពី "ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ", លេខ ២ ស្តីពី "របាយការណ៍លំហូរសាច់ប្រាក់" និង លេខ ១២ ស្តីពី "សន្និធិ" ក្រោយពីទទួលបានមតិយោបល់ពីភាគីពាក់ព័ន្ធ រៀបចំបទបង្ហាញស្តីពី ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១, លេខ ២ និង លេខ ១២
- ➢ ពិនិត្យ និងកែសម្រួលសេចក្តីព្រាងស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១៤ ស្តីពី "ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍", លេខ ២០ ស្តីពី "ការលាតត្រដាងអំពីភាគីពាក់ព័ន្ធ", លេខ ៣២ ស្តីពី "អត្ថប្រយោជន៍និយោជិត" និង លេខ ៤២ ស្តីពី "អត្ថប្រយោជន៍សង្គម"
- ➢ ការងារបណ្តឹងតវ៉ាសម្រាប់ក្នុងឆមាសទី១ ឆ្នាំ២០២៤៖
  - បណ្តឹងតវ៉ាមក ន.គ.ស.៖ សម្របសម្រួលមានចំនួន១១៤, កំណត់ហេតុជួបចំនួន២០៣, រៀបចំលិខិតឆ្លើយតបចំនួន២៨២

- បណ្តឹងតវ៉ាទៅរដ្ឋមន្ត្រីៈកំណត់បង្ហាញរឿងចំនួន២៥,លិខិតលើកយោបល់ ចំនួន២៦ករណី, រៀបចំលិខិតឆ្លើយតបចំនួន២៥

➢ ប្រព័ន្ធ E-Filing សម្រាប់សហគ្រាសសម្រាប់ឆមាសទី១ ឆ្នាំ២០២៤ មានដូចជាៈ
  - ការស្នើសុំលេខអត្តសញ្ញាណកម្មហិរញ្ញវត្ថុ (Fin)មានៈ
    - សហគ្រាសរងសវនកម្មបានទទួលចំនួន១៩១, បញ្ចប់នីតិវិធី ចំនួន១៧៣
    - សហគ្រាសមិនរងសវនកម្មបានទទួលចំនួន៣,០៥២,បញ្ចប់នីតិវិធីចំនួន២,៩០០
  - ការស្នើសុំផ្លាស់ប្តូរប្រភេទសហគ្រាសៈ
    - សហគ្រាសរងសវនកម្មទទួលបានចំនួន១៥, បញ្ចប់នីតិវិធីចំនួន១៤
    - សហគ្រាសមិនរងសវនកម្មទទួលបានចំនួន៦៧, បញ្ចប់នីតិវិធីចំនួន៦៧

➢ ប្រព័ន្ធ E-Filing អង្គភាពមិនស្វែងរកប្រាក់ចំណេញៈ
  - ការស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ (Fin)
    - អង្គភាពរងសវនកម្មទទួលបានចំនួន៧, បញ្ចប់នីតិវិធីចំនួន៥
    - អង្គភាពមិនរងសវនកម្មទទួលបានចំនួន១១២, បញ្ចប់នីតិវិធីចំនួន៨០
  - ស្នើសុំផ្លាសប្តូរប្រភេទអង្គភាព
    - អង្គភាពរងសវនកម្មទទួលបានចំនួន២, បញ្ចប់នីតិវិធីចំនួន ២
    - អង្គភាពមិនរងសវនកម្មទទួលបានចំនួន១, បញ្ចប់នីតិវិធីចំនួន១
  - ការជូនដំណឹងបិទសហគ្រាស
    - សហគ្រាសរងសវនកម្មទទួលបានចំនួន២,បានរៀបចំលិខិតឆ្លើយតបចំនួន៤
    - សហគ្រាសមិនរងសវនកម្មទទួលបានចំនួន១៩៥,បានរៀបចំលិខិតឆ្លើយតបចំនួន១៩៥

➢ សេវាសាធារណៈនិងរដ្ឋបាលសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញៈ
  - ការស្នើសុំពន្យាបញ្ចប់ការងារសវនកម្ម និងបោះផ្សាយមតិសវនកម្មៈ អង្គភាពរងសវនកម្មបានទទួលចំនួន៦,បានរៀបចំលិខិតឆ្លើយតបចំនួន១០
  - ការិយបរិច្ឆេទគណនេយ្យ២០២២ៈ បានរៀបចំលិខិតឆ្លើយតបចំនួន១០
  - ការិយបរិច្ឆេទគណនេយ្យ២០២៣ៈ អង្គភាពរងសវនកម្មបានទទួលចំនួន៦,បានរៀបចំលិខិតឆ្លើយតបចំនួន៩
  - ការជូនដំណឹងបិទអង្គភាពរងសវនកម្មៈ អង្គភាពមិនរងសវនកម្មបានទទួលចំនួន៣, បានរៀបចំលិខិតឆ្លើយតបចំនួន៣
  - ការស្នើសុំបើកប្រព័ន្ធៈអង្គភាពរងសវនកម្មបានទទួលចំនួន៦, បានរៀបចំលិខិតឆ្លើយតបចំនួន៦, អង្គភាពមិនរងសវនកម្មបានទទួលចំនួន៥២, បានរៀបចំលិខិតឆ្លើយតបចំនួន៤៩ៈ
    - ឆ្នាំ២០២១ៈអង្គភាពរងសវនកម្មបានទទួលចំនួន២, បានរៀបចំលិខិតឆ្លើយតបចំនួន២, អង្គភាពមិនរងសវនកម្មទទួលបានចំនួន៣០, បានរៀបចំលិខិតឆ្លើយតបចំនួន២៩
    - ឆ្នាំ២០២២ៈ អង្គភាពរងសវនកម្មបានទទួលចំនួន៣, បានរៀបចំលិខិតឆ្លើយតបចំនួន៣, អង្គភាពមិនរងសវនកម្មបានទទួលចំនួន២០, បានរៀបចំលិខិតឆ្លើយតបចំនួន១៨
    - ឆ្នាំ២០២៣ៈ អង្គភាពរងសវនកម្មបានទទួលចំនួន១, បានរៀបចំលិខិតឆ្លើយតបចំនួន១, អង្គភាពមិនរងសវនកម្មបានទទួលចំនួន១, បានរៀបចំលិខិតឆ្លើយតបចំនួន១

➢ ការងារពាក់ព័ន្ធពិន័យអន្តរការណ៍សម្រាប់ខែឆមាសទី១ ឆ្នាំ២០២៤ ៈ
  - ឆ្នាំ២០២០ៈបានរៀបចំលិខិតពិន័យសហគ្រាសរងសវនកម្មបានចំនួន២៧, បានបង់ប្រាក់ពិន័យចំនួន៥
  - ឆ្នាំ២០២១ៈ សហគ្រាសរងសវនកម្មមានចំនួន១

➢ បានផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីៈគណនេយ្យនិងសវនកម្ម សម្រាប់នីតិបុគ្គល និងរូបវន្តបុគ្គលដូចខាងក្រោមៈ
  - អាជ្ញាបណ្ណនីតិបុគ្គល (សរុបមានចំនួន ៤៤ក្រុមហ៊ុន)
    - អាជ្ញាបណ្ណគណនេយ្យកម្រិត១ៈចំនួន ០២ក្រុមហ៊ុន
    - អាជ្ញាបណ្ណគណនេយ្យកម្រិត២ៈចំនួន ២២ ក្រុមហ៊ុន

        ○ អាជ្ញាបណ្ណសវនកម្ម៖ ចំនួន ២០ក្រុមហ៊ុន
- អាជ្ញាបណ្ណរូបវន្តបុគ្គល (សរុបមានចំនួន ៣៨រូប)
    - ជនជាតិខ្មែរ (សរុបមានចំនួន ៣៥នាក់)
    - អាជ្ញាបណ្ណគណនេយ្យករម្រិត២៖ ចំនួន ២៤រូប
    - អាជ្ញាបណ្ណសវនកម្ម ៖ ចំនួន ១២រូប
    - ជនជាតិបរទេស (សរុបមានចំនួន ០២រូប)
    - អាជ្ញាបណ្ណគណនេយ្យករម្រិត១៖ ចំនួន ០២រូប។

## ២.ការខារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ

គោលបំណងគោលនយោបាយទី២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺ "ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" ដែលមានកម្មវិធីចំនួន៣។ លទ្ធផលនៃការអនុវត្តប្រចាំឆមាសទី១ ឆ្នាំ២០២៤ នៃការអនុវត្តនៃគោលបំណងគោលនយោបាយទី២ នេះ មានដូចក្នុងរបាយការណ៍ខាងក្រោមនេះ៖

### ២.១. ការកៀរគរចំណូលថវិកាជាតិ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មានបេសកកម្មសំខាន់ៗក្នុងនោះ ៖ ១.ទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលអាករ និងកម្រៃផ្សេងៗ លើទំនិញនាំចេញ ឬនាំចូល ស្របតាមបញ្ញត្តិ ស្ដីពីគយ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល ការធ្វើចរាចរ និងការធ្វើសន្និធិទំនិញ ២.ដាក់បទប្បញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំចេញ ឬនាំចូល ៣. ជំរុញការបង្ការ និងបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ ៤.ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ៥. ជំរុញអនុវត្តតាមស្តង់ដារអន្តរជាតិ និងឧត្តមានុវត្តន៍ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យគយ និងការសម្រួលពាណិជ្ជកម្ម ជាពិសេស ការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ និងការធ្វើស្វ័យប្រវត្តិកម្មគយ[2]។ ដោយឡែកអគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មសំខាន់ៗ ក្នុងនោះ ១. ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ២. អនុវត្តកម្មវិធីចាប់បង្ខំ ដោយធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ អនុវត្តទោសទណ្ឌ តាមការកំណត់ស្តីពីពន្ធដារ ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ៣. ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ ៤. ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ ៥. អនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ ៦. អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ ៧. បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ក្រសួង ធ្វើឱ្យមានភាពសាមញ្ញ ចំពោះតម្រូវការផ្សេងៗ និងបន្ថយចំណាយរបស់អ្នកជាប់ពន្ធ ៨.បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព ៩.បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារ ដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន[3]។ ផ្នែកនេះក៏ចូលរួមអនុវត្តដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ[4]។ ជាលទ្ធផលប្រចាំឆមាសទី១ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានបានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

---

[2] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[3] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[4] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.១.១. ការប្រមូលចំណូលសារពើពន្ធ

- **ការគ្រប់គ្រងចំណូលពន្ធដារ**
    - លទ្ធផលរួមនៃចំណូលពន្ធ-អាករនានា៖ សរុបរយៈពេល ៦ខែ ឆ្នាំ២០២៤ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ៧ ៧៦៧,៧៣ ប៊ីលានរៀល (ប្រមាណជា ១ ៩១៧,៩៦ លានដុល្លារ) ស្មើនឹង ៤៦,០៦% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០២៤ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ឃើញថាថយចុះចំនួន ៦២៥,៤៤ ប៊ីលានរៀល (ប្រមាណជា ១៥៤,៤៣ លានដុល្លារ) ស្មើនឹង -៧,៤៥%
    - លទ្ធផលនៃចំណូលពន្ធ-អាករនានាបានបង់ចូលថវិកាជាតិ៖ សរុបរយៈពេល ៦ខែ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានធ្វើបែបបទបង់ចូលថវិកាជាតិសរុបចំនួន ៧ ៧៧៦,៦៩ ប៊ីលានរៀល (ប្រមាណជា ១ ៩២០,១៧ លានដុល្លារ) ស្មើនឹង ៤៦,១១% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំក្នុងនោះ៖
        - ថវិកាថ្នាក់ជាតិ ចំនួន ៧ ០០៩,៤៥ ប៊ីលានរៀល (ប្រមាណជា ១ ៧៣០,៧៣ លានដុល្លារ)
        - ថវិកាថ្នាក់ក្រោមជាតិ ចំនួន ៧៦២,៦៤ ប៊ីលានរៀល (ប្រមាណជា ១៨៨,៣០ លានដុល្លារ)
        - ចំណូលមិនមែនសារពើពន្ធ ចំនួន ៤,៦០ ប៊ីលានរៀល (ប្រមាណជា ១,១៣ លានដុល្លារ)

    - លទ្ធផលចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ៖ សម្រាប់រយៈពេល ៦ខែ ឆ្នាំ២០២៤ នេះ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលប្រមូលតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបែងចែកតាមប្រភេទអ្នកជាប់ពន្ធ ដូចខាងក្រោម៖
        - អ្នកជាប់ពន្ធធំ ចំនួន ៦ ០៥៦,៧៣ ប៊ីលានរៀល (ប្រមាណជា ១ ៤៩៥,៤៩ លានដុល្លារ) ស្មើនឹង ៧៧,៩៧% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ចំណូលតាមប្រភេទអ្នកជាប់ពន្ធធំថយចុះចំនួន ៦៤៩,៣៧ ប៊ីលានរៀល (ប្រមាណជា ១៦០,៣១ លានដុល្លារ) ស្មើនឹង -៩,៦៨%
        - អ្នកជាប់ពន្ធមធ្យម ចំនួន ១ ២៥៧,៥០ ប៊ីលានរៀល (ប្រមាណជា ៣១០,៤៩ លានដុល្លារ) ស្មើនឹង ១៦,១៩% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ចំណូលតាមប្រភេទអ្នកជាប់ពន្ធមធ្យមកើនឡើងចំនួន ៤០,៧២ ប៊ីលានរៀល (ប្រមាណជា ១០,០៥ លានដុល្លារ) ស្មើនឹង ៣,៣៥%
        - អ្នកជាប់ពន្ធតូច ចំនួន ៥២,៣២ ប៊ីលានរៀល (ប្រមាណជា ១២,៩២ លានដុល្លារ) ស្មើនឹង ០,៦៧% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ចំណូលតាមប្រភេទអ្នកជាប់ពន្ធតូចកើនឡើងចំនួន ៥,៤៩ ប៊ីលានរៀល (ប្រមាណជា ១,៣៥ លានដុល្លារ) ស្មើនឹង ១១,៧២%
        - ផ្សេងៗ (ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ) ចំនួន ៤០១,១៧ ប៊ីលានរៀល (ប្រមាណជា ៩៩,០៥ លានដុល្លារ) ស្មើនឹង ៥,១៦% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ចំណូលពន្ធផ្សេងៗថយចុះចំនួន ២២,៨១ ប៊ីលានរៀល (ប្រមាណជា ៥,៦៣ លានដុល្លារ) ស្មើនឹង -៥,៣៨%
    - សម្រាប់រយៈពេល ៦ខែ ឆ្នាំ២០២៤ បានពិនិត្យនិងអនុម័តលើឯកសារស្នើសុំចុះបញ្ជីពន្ធដារចំនួន ៦ ១៤៣ សហគ្រាស (ពន្ធធំ ៣១៧ ពន្ធមធ្យម ២ ៩៣០ ពន្ធតូច ២ ៨៩៦) ដូចខាងក្រោម៖
        - សហគ្រាសបានចុះបញ្ជីជោគជ័យចំនួន ៥ ១៤៤ សហគ្រាស (ពន្ធធំ ៣០៦ ពន្ធមធ្យម ២ ៣៣៣ ពន្ធតូច ២ ៥០៥) ក្នុងនោះតាមថ្នាលចំនួន ៤ ៧៨៤ សហគ្រាស (ពន្ធធំ ២៨៥ ពន្ធមធ្យម ២ ១៦៣ ពន្ធតូច ២ ៣៣៦)

- សហគ្រាសត្រូវបានកំណត់ថាមានហានិភ័យចំនួន ៩៩៩ សហគ្រាស (ពន្ធធំ ១១ ពន្ធមធ្យម ៥៩៧ ពន្ធតូច ៣៩១) ក្នុងនោះតាមថ្នាលចំនួន ៩៨៥ សហគ្រាស (ពន្ធធំ ៩ ពន្ធមធ្យម ៥៩១ ពន្ធតូច ៣៨៥) ដោយបានបដិសេធការចុះបញ្ជីចំនួន ២២៤ សហគ្រាស និងអនុម័តបញ្ជូនពិនិត្យបន្ថែមចំនួន ៧៧៥ សហគ្រាស
  - គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ឯកសារសល់យោងចុងគ្រាមានចំនួន ១២០ សហគ្រាស ក្នុងនោះតាមថ្នាលចំនួន ១០២ សហគ្រាស
- សម្រាប់រយៈពេល ៦ខែ ឆ្នាំ២០២៤ បានពិនិត្យនិងអនុម័តចំនួន ៥ ៩៧៧ ករណី ដូចខាងក្រោម៖
  - បានធ្វើបច្ចុប្បន្នភាពព័ត៌មានចំនួន ៥ ៦៦០ ករណី (ពន្ធធំ ១ ៨៦០ ពន្ធមធ្យម ៣ ១៤៤ ពន្ធតូច ៦៥៦) ក្នុងនោះបង្កើតសាខាថ្មីចំនួន ៣៥៥ សាខា និងផ្ទេរការគ្រប់គ្រងចំនួន ៧៦២ ករណី
  - បានចេញលិខិតឆ្លើយតបជូនអ្នកជាប់ពន្ធ ដើម្បីផ្តល់ឯកសារតម្រូវឬសហការជាមួយសាមីអង្គភាពគ្រប់គ្រងបន្តនីតិវិធី ចំនួន ៣១៧ ករណី (ពន្ធធំ ៧២ ពន្ធមធ្យម ២០៩ ពន្ធតូច ៣៦)
  - ឯកសារស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានកំពុងស្ថិតក្នុងដំណើរការបន្តពិនិត្យមានចំនួន ១ ០០៩ ករណី (ពន្ធធំ ៤៣៧ ពន្ធមធ្យម ៤៦៩ ពន្ធតូច ១០៣)
- ការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ថតរូប-ស្កេនម្រាមដៃ៖ សម្រាប់ រយៈពេល ៦ខែ ឆ្នាំ២០២៤ មានសរុបចំនួន ៦ ១៧២ សហគ្រាស (ពន្ធធំ ២៣១ ពន្ធមធ្យម ២ ៦៩៨ ពន្ធតូច ៣ ២៤៣)
- លទ្ធផលការងារផ្នែកសវនកម្ម៖ សរុបរយៈពេល ៦ខែ ឆ្នាំ២០២៤ នេះ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសសរុបចំនួន ៦ ៤១៨ ករណី មានប្រាក់ពន្ធចំនួន ៣ ៥៣៩,០៣ ប៊ីលានរៀល (ប្រមាណជា ៨៧៣,៨៣ លានដុល្លារ) ធៀបនឹងរយៈពេលដូចគ្នាក្នុង ឆ្នាំ២០២៣ ឃើញថាថយចុះចំនួន ១២៨ ករណី ស្មើនឹង -១,៩៦% និងមានប្រាក់ពន្ធថយចុះចំនួន ២ ៧៣៥,៣៩ ប៊ីលានរៀល (ប្រមាណ ៦៧៥,២៤០ លានដុល្លារ) ស្មើនឹង -៤៣,៦០%
- លទ្ធផលការងារគ្រប់គ្រងប្រមូលបំណុលពន្ធ៖ សរុបក្នុងរយៈពេល ៦ខែ ឆ្នាំ២០២៤ បំណុលពន្ធប្រមូលបានមានចំនួន ៣៤៧,៨៥ ប៊ីលានរៀល (ប្រមាណជា ៨៥,៨៩ លានដុល្លារ) ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ មានចំនួន ៤៧០,៥៩ ប៊ីលានរៀល (ប្រមាណជា ១១៦,១៩ លានដុល្លារ) គឺមានការថយចុះចំនួន ១២២,៧៤ ប៊ីលានរៀល (ប្រមាណជា ៣០,៣០ លានដុល្លារ) ស្មើនឹង -២៦,០៨%
- លទ្ធផលការងារដោះស្រាយវិវាទ៖ សរុបក្នុងរយៈពេល ៦ខែ ឆ្នាំ២០២៤ មានសំណុំឯកសារបណ្តឹងតវ៉ាកំពុងដំណើរការមានចំនួន ១ ៤២៤ ករណី ដែលក្នុងនោះបានទទួលពាក្យស្នើសុំថ្មីចំនួន ៩៤៨ ករណី និងសល់យោងគ្រាមុនមានចំនួន ៤៧៦ ករណី។ ជាលទ្ធផល បានដោះស្រាយសំណុំឯកសារបណ្តឹងតវ៉ាចំនួន ៥១៨ ករណី មានប្រាក់ពន្ធ ៩៩៣,០៦ ប៊ីលានរៀល ប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ គឺមានការកើនឡើងចំនួន ៣១៧ ករណី ប្រាក់ពន្ធកើនឡើងចំនួន ៩៤៧,៥៣ ប៊ីលានរៀល។ បំណុលពន្ធបានបង់ក្នុងរយៈពេល ៦ខែ ឆ្នាំ២០២៤ មានចំនួន ១៥,២៦ ប៊ីលានរៀល ប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ កើនឡើងចំនួន ៦,៧៤ ប៊ីលានរៀល។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ សំណុំឯកសារនៅសល់ចុងគ្រាសរុបមានចំនួន ៤៧៦ ឯកសារ
- ការកែទម្រង់គោលនយោបាយសារពើពន្ធ៖ សរុបរយៈពេល ៦ខែ ឆ្នាំ២០២៤ មានរៀបចំបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពន្ធដារចំនួន ២៩ ក្នុងនោះ អនុក្រឹត្យចំនួន ៣, ប្រកាសចំនួន ១៥, សេចក្តីណែនាំចំនួន ៤ និងសេចក្តីជូនដំណឹងចំនួន ៧
- ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ៖ សរុបក្នុងរយៈពេល ៦ខែ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានបញ្ចប់ការអភិវឌ្ឍប្រព័ន្ធកម្មវិធីសរុបចំនួន ១ និងបញ្ចប់ការងារធ្វើបច្ចុប្បន្នភាពប្រព័ន្ធកម្មវិធីសរុបចំនួន ៣៣ (ស្មើនឹង ១៥៧ លើក)

- ការអនុវត្តកិច្ចព្រមព្រៀង៖ សរុបរយៈពេល ៦ខែ ឆ្នាំ២០២៤ មានសំណុំឯកសារស្នើសុំអត្ថប្រយោជន៍ពីការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា សរុបចំនួន ៤១៧សហគ្រាស ហើយបានពិនិត្យ និងសម្រេចចំនួន ២៧៥ សហគ្រាស ប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ កើនឡើងចំនួន ៥៣ សហគ្រាស ស្មើនឹង ២៣,៨៧% និងមានសហគ្រាសស្នើសុំដកពាក្យស្នើសុំ ចំនួន ២០ ករណី។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ មានសំណុំឯកសារកំពុងស្ថិតក្នុងដំណើរការចំនួន ១២២ សហគ្រាស
- វឌ្ឍនភាពថ្មីៗនៃកិច្ចសហប្រតិបត្តិការផ្នែកពន្ធដារ៖ សរុបរយៈពេល ៦ខែ ឆ្នាំ២០២៤ មានចំនួន ២៦២ លើក ក្នុងនោះ ជាមួយស្ថាប័នជាតិ ចំនួន ២៣០ លើក, ស្ថាប័នអន្តរជាតិ ៥ លើក និងវិស័យឯកជននិងអង្គការសមាគមចំនួន ២៨ លើក។

➢ **ការគ្រប់គ្រងចំណូលគយ និងរដ្ឋាករកម្ពុជា**

- ចំណូលសរុប៖ ក្នុងឆមាសទី១ ឆ្នាំ២០២៤ អគរ ប្រមូលចំណូលបានចំនួន ៤ ៩៦៦,៨៧ ប៊ីលានរៀល ស្មើនឹង ១ ២១៨,៧០ លានដុល្លារអាមេរិក ត្រូវជាប្រមាណ ៤៤,២៥% នៃផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ កើនឡើង ៣១១,៤៤ ប៊ីលានរៀល ស្មើនឹង ៧៦,៤២ លានដុល្លារអាមេរិក ត្រូវជាប្រមាណ ៦,៦៩% បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២៣

ក្រាហ្វិកចំណូលតាមប្រភេទពន្ធនិងអាករ ក្នុងឆមាសទី១ ឆ្នាំ២០២៣ និងឆមាសទី១ ឆ្នាំ២០២៤




ក្រាហ្វិកចំណូលតាមក្រុមទំនិញក្នុងឆមាសទី១ ឆ្នាំ២០២៣ និងឆមាសទី១ ឆ្នាំ២០២៤




- ពន្ធនិងអាករជាបន្ទុករបស់រដ្ឋ៖ ក្នុងឆមាសទី១ ឆ្នាំ២០២៤ ពន្ធនិងអាករជាបន្ទុករបស់រដ្ឋមានចំនួន ៧ ០៧៧,៣៨ ប៊ីលានរៀល ស្មើនឹង ១ ៧៣៦,៥៩ លានដុល្លារអាមេរិក កើនឡើង ៣៨៦,៣៨ ប៊ីលានរៀល ត្រូវជាប្រមាណ ៥,៧៧% បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២៣។ ប្រាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋនេះ មានទំហំប្រមាណ ១៤២,៤៩% នៃចំណូលពន្ធនិងអាករដែលប្រមូលបានក្នុងឆមាសទី១ ឆ្នាំ២០២៤។ បើប្រៀបធៀបនឹងឆមាសទី ១ ឆ្នាំ២០២៣ ពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងវិស័យវិនិយោគកាត់ដេរ កើនឡើង ៩,៩១%, ពន្ធនិងអាករជា

បន្ទុករបស់រដ្ឋក្នុងវិស័យវិនិយោគមិនមែនកាត់ដេរ កើនឡើង ១,២៤% និងមុខសញ្ញាផ្សេងទៀតដូចជា ក្រសួង-ស្ថាប័នរដ្ឋ អង្គការ ស្ថានទូត និងជំនួយបរទេស ជាដើម កើនឡើង ៣,៥៥%

**ក្រាហ្វិកពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងឆមាសទី១ ឆ្នាំ២០២៣ និងឆមាសទី១ ឆ្នាំ២០២៤**




- ការបាត់បង់ចំណូលពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs)៖ ក្នុងឆមាសទី១ ឆ្នាំ២០២៤ ការបាត់បង់ចំណូលពន្ធគយដោយការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមាន ៨១១,២៣ ប៊ីលានរៀល ស្មើនឹង ១៩៩,០៣ លានដុល្លារអាមេរិក ថយចុះ ៥៨,៣០ ប៊ីលានរៀល ត្រូវជា ៦,៧០% បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ ២០២៣
- ការបង្ការនិងបង្ក្រាបអំពើរត់គេចពន្ធ៖ ក្នុងឆមាសទី១ ឆ្នាំ២០២៤ អគរ បានបង្ក្រាបបទល្មើសរត់គេចពន្ធចំនួន ១១ ១៤១ ករណី រួមមាន ករណីធំ ៥០៧ ករណី និងករណីតូច ១០ ៦៣៤ ករណី។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២៣ ចំនួនករណីដែលបង្ក្រាបបានក្នុងឆមាសទី១ ឆ្នាំ២០២៤នេះ ថយចុះ ៨ ៩៤០ ករណី ឬ ៤៤,៥២%។ ទន្ទឹមនេះ អគរ បានដោះស្រាយកំណត់ហេតុបទល្មើសគយរួចចំនួន ១១ ០៨០ ករណី ដោយប្រមូលបានប្រាក់ពន្ធអាករនិងពិន័យចំនួន ៧០,១២ ប៊ីលានរៀល។ មុខទំនិញល្មើសសំខាន់ៗដែលបង្ក្រាបបានរួមមាន៖ ផលិតផលតេលសិលា ២៦៥ ១៨៦ លីត្រ, រថយន្ត ១២៦ គ្រឿង (ចង្កូតស្តាំ ១២ គ្រឿង), ទោចក្រយានយន្ត ១០ ០០៣ គ្រឿង, ម៉ាស៊ីនត្រជាក់ ១ ៩៩១ គ្រឿង, ទូរទស្សន៍ ១៥៥ គ្រឿង, ទូទឹកកក ២១៧ គ្រឿង, ម៉ាស៊ីនបោកខោអាវ ១៤០ គ្រឿង, ទូរសព្ទដៃ ៣ ៨៦២ គ្រឿង, បរិក្ខារកុំព្យូទ័រចម្រុះ ៤៣០ គ្រឿង, បរិក្ខារអគ្គិសនីចម្រុះ ៦៧ ៦៧៦,៥០ គីឡូក្រាម, បារី ៣ ០០៤ កេស, អាគុយ ៣ ៦៦៤ រាយ, ស្រាបរទេស ៣ ៥៩៨ កេស, ស្រាបៀរ ១ ០៧១ កេស, ភេសជ្ជៈផ្សេងទៀត ៣១ ៣១០ កេស, គ្រឿងឧបភោគបរិភោគ ៤៤៨,២៥ តោន សម្ភារសំណង់ ៣៩០,៥៤ តោន និងរូបិយប័ណ្ណបរទេស ៤៦០ ០០០ USD ព្រមទាំងមុខទំនិញមួយចំនួនផ្សេងទៀត។ ទន្ទឹមនេះ អគរ ក៏បានបង្ក្រាបនូវទំនិញហាមឃាត់មួយចំនួន រួមមាន សាច់បង្កកនិងផលិតផលពីសាច់សត្វខូចគុណភាព ២៤ ករណី ស្មើនឹង ៥២,១០ តោន, គ្រឿងញៀន ៩ ៥៧៦,៤១ ក្រាម (មេតំហ្វេតាមីន, កេតាមីន, ហេរ៉ូអ៊ីន, និងអ៊ិចស្តាស៊ី)

### ២.១.២. ការគៀគរចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ

- បានចុះបេសកកម្មនៅខេត្តព្រះសីហនុ ដើម្បីចូលរួមចុះពិនិត្យស្រាវជ្រាវ និងវាយតម្លៃដាក់ស្តែងផ្ទៃដីរបស់ចម្ការកៅស៊ូឡាបានសៀក ខេត្តរតនគិរី
- បានបើកផ្តល់បង្កាន់ដៃបង់ប្រាក់សរុបចំនួន ១៤៧ ៤៨៩ ក្បាល ក្នុងនោះ សម្រាប់ការប្រើប្រាស់ប្រមូលចំណូលនៅរដ្ឋបាលថ្នាក់ជាតិចំនួន ៣២ ៨៥១ ក្បាល និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ១១៤ ៦៣៨ ក្បាល
- បើកផ្តល់ទិដ្ឋាការស្អិតជូនក្រសួងមហាផ្ទៃ សរុបចំនួន ៦៧.០០០ សន្លឹក
- ការប្រមូលចំណូលប្រចាំខែ ឧសភា ឆ្នាំ ២០២៤ សម្រេចបាន ៤៣៤ ១៩៤,៥ លានរៀល ស្មើនឹង ២៤,៧% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២៤ និងនិងរយៈពេល ៥ខែ ឆ្នាំ២០២៤ សម្រេចបាន ១ ០៣៣ ៤៣២,២ លានរៀល ស្មើនឹង ៥៨,៧% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២៤

- បានចុះសិក្សាស្រាវជ្រាវ ពិនិត្យ និងប្រមូលព័ត៌មានអំពីការដឹកជញ្ជូនខ្សាច់តាមដងទន្លេ នៅភូមិសាស្ត្ររាជធានីភ្នំពេញ និងខេត្តកណ្ដាល
- បានជំរុញបន្ថែមលើកិច្ចការធ្វើប័ណ្ណកម្មសិទ្ធិដីរដ្ឋនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមតាមរយៈកិច្ចប្រជុំពិនិត្យ និងវាយតម្លៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២៣ របស់ក្រសួង ស្ថាប័ន ចំនួន ១៩ និងខេត្ត ចំនួន ៨
- បានចុះបំពេញបេសកកម្មទៅខេត្តកំពង់ចាម ដើម្បីចូលរួមពិនិត្យ និងវាយតម្លៃជាក់ស្ដែង លើករណីការស្នើសុំកែសម្រួលទំហំផ្ទៃក្រឡាអចលនវត្ថុក្នុងបញ្ជី សារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ឱ្យត្រូវជាមួយផ្ទៃក្រឡានៅលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចំនួន ១៣ ក្បាលដី ខេត្តកំពង់ចាម
- បានធ្វើបច្ចុប្បន្នភាពទិន្នន័យ និងបានបូកសរុបតួលេខចំណូលមិនមិនសារពើពន្ធថ្នាក់ជាតិឆ្នាំ ២០២៣ (គិតត្រឹមថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤) ដែលមានចំនួន ២ ៧៥៨ ៣៨៨,០៧ លានរៀល ស្មើនឹង១២៨,៧៥% ធៀបច្បាប់ឆ្នាំ២០២៣
- បានធ្វើបច្ចុប្បន្នភាពទិន្នន័យ និងបានបូកសរុបតួលេខចំណូលមិនមិនសារពើពន្ធថ្នាក់ជាតិឆ្នាំ ២០២៤ (គិតត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤) ដែលមានចំនួន ១ ៣០៧ ២០០,៨៦ លានរៀល ស្មើនឹង៤២,៤៨% ធៀបច្បាប់ឆ្នាំ២០២៤។

## ២.២. ការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការគ្រប់គ្រងចំណាយសាធារណៈ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ។ អគ្គនាយកដ្ឋានថវិកាមានបេសកម្មក្នុងការគ្រប់គ្រងថវិកាជាតិហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋក្នុងគោលដៅធានាឱ្យមានការបែងចែកធនធានថវិការដ្ឋប្រកបដោយប្រសិទ្ធភាព ស័ក្តសិទ្ធិភាព និងចីរភាព[5]។ រីឯ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល បំពេញបេសកកម្មសំខាន់ លើការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋប្រកបដោយប្រសិទ្ធភាព ស័ក្តសិទ្ធិភាព និងចីរភាព[6]។ អគ្គនាយកដ្ឋានរតនាគារជាតិ មានបេសកកម្មសំខាន់លើ ១. ជាបេឡាករ និងគណនេយ្យករសាធារណៈ របស់រាជរដ្ឋាភិបាល ២.គ្រប់គ្រងប្រាក់កាក់របស់រដ្ឋ និងគណនីពិសេសរបស់រតនាគារ ៣.រៀបចំគោលការណ៍និងបទបញ្ញាគណនេយ្យសាធារណៈ ៤.កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី ៥.ធានាតុល្យភាពទូទៅនៃគណនី ៦.តម្រង់ទិសនិងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងបំណុលសាធារណៈ ៧.សហការជាមួយធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ៨.កសាងសេចក្តីព្រាងច្បាប់សម្រាប់ទូទាត់ថវិកាប្រចាំឆ្នាំ[7]។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានបេសកកម្មសំខាន់ លើការគ្រប់គ្រងលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់អគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ បំពេញបេសកកម្មលើការគ្រប់គ្រង និងការវិភាជថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា។ អង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនក៏ត្រូវបានអនុវត្តក្នុងផ្នែកនេះផងដែរ។ អង្គភាពនេះជំរុញ សម្របសម្រួល និងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ជាលទ្ធផលអគ្គនាយកដ្ឋាន និងអង្គភាពបានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោមៈ

### ២.២.១. ការគ្រប់គ្រង និងការអនុវត្តថវិកា

- **ការរៀបចំថវិកា**
  - បន្តធ្វើបច្ចុប្បន្នភាពលើ អង្គភាពថវិកា ចំណាត់ថ្នាក់រដ្ឋបាល ចំណាត់ថ្នាក់កម្មវិធី របស់ក្រសួង-ស្ថាប័នសម្រាប់ថវិកាឆ្នាំ២០២៤
  - បានជួយក្រសួង-ស្ថាប័ន និងនាយកដ្ឋានហិរញ្ញកិច្ចក្នុងការកែតម្រូវទិន្នន័យ របស់ក្រសួង-ស្ថាប័ន នៅក្នុងប្រព័ន្ធ FMIS ដើម្បីបិទបញ្ជី ឆ្នាំ២០២៣
  - បានចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពជនបង្គោល និងបញ្ចូលទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ CPIMS នៅខេត្តសៀមរាប

---

[5] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[6] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[7] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




ថវិកាសង្ខេប ឆ្នាំ២០២៤
BUDGET IN BRIEF FISCAL YEAR 2024

- បានបន្តផ្ទៀងផ្ទាត់របាយការណ៍ R06, R20 និង R42 ឆ្នាំ ២០២៣ ដែលបានទាញចេញពីប្រព័ន្ធ FMIS ដើម្បីត្រៀមបិទបញ្ជីនៅក្នុងប្រព័ន្ធ
- សម្របសម្រួលជួយជាជំនួយបច្ចេកទេសនិងដោះ លើបញ្ហាសម្រាប់ការគ្រោងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧ និងការគ្រោងថវិកាឆ្នាំ២០២៥
- បានចូលរួមសិក្ខាពិគ្រោះយោបល់ដើម្បីប្រមូលធាតុចូលសម្រាប់ការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការពិនិត្យឡើងវិញនៃចំណាយសាធារណៈ
- បានផ្តល់មតិយោបល់លើសៀវភៅ "Public Financial Management Reform for Structural Transformation: Fiscal Coordination between National and Sub-National Administrations Cambodia" និង "Economic and Social Status, and Cambodia on Fiscal Sustainability In An Open Economy" និងចូលរួមសិក្ខាសាលាពិគ្រោះយោបល់ នៅសណ្ឋាគារ Raffles Le Royal។

➢ **ការអនុវត្តថវិកា**

- ចំណាយចរន្ត
  - ការងារត្រួតពិនិត្យការអនុវត្តចំណាយថវិកាចរន្ត
    - អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឱ្យអនុវត្ត
    - ប្រកាសលេខ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រូវបានដាក់ឱ្យអនុវត្ត
  - ការអនុវត្តប្រព័ន្ធ FMIS៖ បានពិនិត្យនិងផ្តល់យោបល់លើសំណើសុំគោលការណ៍ធានាចំណាយរបស់ក្រសួងស្ថាប័នចំនួន ៣៧ រួមទាំងប្រាក់ឧបត្ថម្ភធនរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ឱ្យស្របតាមបរិបទ FMIS តាមនីតិវិធីចាស់ និងនីតិវិធីតម្រង់ទិសថ្មី
- ចំណាយវិនិយោគ
  - ជំពូក២១ (គម្រោងវិនិយោគផ្ទាល់)៖ បានផ្តល់ធានាចំណាយជូន ក្រសួងសាធារណការនិងដឹកជញ្ជូនសរុបចំនួន ៧៥គម្រោង, ក្រសួងអភិវឌ្ឍន៍ជនបទសរុបចំនួន ៤៩គម្រោង, ក្រសួងធនធានទឹក និងឧតុនិយមសរុបចំនួន ២៧គម្រោង, ក្រសួងអប់រំ យុវជន និងកីឡាសរុបចំនួន ៥គម្រោង, ក្រសួងមហាផ្ទៃសរុបចំនួន ៣គម្រោង, ក្រសួងសុខាភិបាលសរុបចំនួន ៤គម្រោង, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួន ១គម្រោង, ក្រសួងស្ថាប័ន-ផ្សេងៗចំនួន ១១គម្រោង
  - ជំពូក៦១ (ការងារជួសជុល និងថែទាំ)៖ បានផ្តល់ធានាចំណាយជូន ក្រសួងសាធារណការនិងដឹកជញ្ជូនសរុបចំនួន ១១គម្រោង, ក្រសួងអភិវឌ្ឍន៍ជនបទសរុបចំនួន ៧០គម្រោង, ក្រសួងធនធានទឹក និងឧតុនិយមសរុបចំនួន ១គម្រោង។

## ២.២.២. ការគ្រប់គ្រងចំណាយសាធារណៈ

➢ **ការគ្រប់គ្រងចំណាយសាធារណៈថ្នាក់ជាតិ**

- បានអនុម័តលើតារាងផែនការលទ្ធកម្មកែតម្រូវចំនួន ៤៦ឯកសារ រួមមាន៖ ក្រសួងស្ថាប័នចំនួន ១១ឯកសារ រដ្ឋបាលរាជធានី-ខេត្ត ចំនួន ៣០ឯកសារ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៥ឯកសារ
- បានពិនិត្យនិងលើកយោបល់លើតារាងផែនការលទ្ធកម្មកែតម្រូវចំនួន ១២ឯកសារ រួមមាន៖ ក្រសួងស្ថាប័នចំនួន ២ឯកសារ រដ្ឋបាលរាជធានី-ខេត្ត ចំនួន ៨ឯកសារ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២ឯកសារ

- បានសម្រេចការចុះត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ បានចំនួន ៦៧ស្ថាប័ន រួមមាន៖ ស្ថាប័នអនុវត្តលទ្ធកម្មនៅរដ្ឋបាលថ្នាក់ជាតិ ខេត្តចំនួន ៦ស្ថាប័ន, ស្ថាប័នអនុវត្តលទ្ធកម្មនៅរដ្ឋបាលរាជធានី ខេត្តចំនួន ១០ស្ថាប័ន, ស្ថាប័នអនុវត្តលទ្ធកម្មអង្គភាពស្វយ័តចំនួន ១៩ស្ថាប័ន, ស្ថាប័នអនុវត្តលទ្ធកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន ៣២ស្ថាប័ន, ក្រុមលទ្ធកម្មនៃអង្គភាពថវិកាថ្នាក់កណ្តាលចំនួន ៤អង្គភាពថវិកា និងក្រុមលទ្ធកម្មនៃអង្គភាពថវិកាថ្នាក់មូលដ្ឋានចំនួន ២៤៥អង្គភាពថវិកា
- បានពិនិត្យនិងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃចំនួន ១៨៦គម្រោង
- បានចូលរួមប្រជុំចរចាថ្លៃចំនួន ៣៦៤គម្រោង
- បានចូលរួមប្រជុំបើកឯកសារដេញថ្លៃ (លើសិទ្ធិ)ចំនួន ១៣៣គម្រោង និងពិគ្រោះថ្លៃ និងស្នងតម្លៃ (ក្រោមសិទ្ធិ) ចំនួន ៧៤២គម្រោង
- បានត្រួតពិនិត្យលើឯកសារកិច្ចសន្យាចំនួន ៤២៥គម្រោង
- បានប្រគល់កិច្ចសន្យាចំនួន ១៨៦គម្រោង
- បានចូលរួមត្រួតពិនិត្យវាយតម្លៃលទ្ធផលការងារ បញ្ចប់សុពលភាព ប្រគល់-ទទួល ទំនិញ សំណង់ និងសេវាកម្ម (លើសិទ្ធិ) ចំនួន ៤៨៨គម្រោង និង(ក្រោមសិទ្ធិ)ចំនួន ៥០៥គម្រោង
- បានបណ្តុះបណ្តាលជំនាញកិច្ចបញ្ជីកាគណនេយ្យរដ្ឋទេយ្យបុរេប្រទានដល់បេឡាជាតិសន្តិសុខសង្គម (បសស)
- បានរៀបចំលិខិតក្នុងនាមអគ្គនាយកដ្ឋានរតនាគារជាតិរំលឹកការជម្រះសមតុល្យគណនីលទ្ធផលនៃការិយបរិច្ឆេទឆ្នាំ២០២៣ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានចុះត្រួតពិនិត្យកិច្ចបញ្ជិកាគណនេយ្យ ឆ្នាំ២០២៣ និងបណ្តាឆ្នាំពាក់ព័ន្ធ និងពិនិត្យប្រតិបត្តិការក្នុងប្រព័ន្ធ FMIS ក្នុងការរៀបចំតារាងតុល្យភាពគណនី របាយការណ៍ចំណូល-ចំណាយ និងចូលរួមជាមួយនាយកដ្ឋានបណ្ណសារ នៃអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជម្រះឯកសារដែលអស់សុពលភាព នៅរតនាគារខេត្តទាំង២៣
- ការចុះកិច្ចព្រមព្រៀង (ចាប់ពីខែមករា-មិថុនា ឆ្នាំ២០២៤) ៖ ហិរញ្ញប្បទានឥតសំណង៖ បានចុះកិច្ចព្រមព្រៀងចំនួន ៩ ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ១២៤,៥៧ លានដុល្លារអាមេរិក ដែលមានដូចខាងក្រោម៖
  - ដៃគូអភិវឌ្ឍន៍ពហុភាគី៖ បានចុះកិច្ចព្រមព្រៀងចំនួន ៩ ដែលមានទឹកប្រាក់សរុបចំនួន ១២៤,៥៧ លានដុល្លារអាមេរិក
- ឥណទានសម្បទាន៖ បានចុះកិច្ចព្រមព្រៀងចំនួន ៤ ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ៣១៣,៧៨ លានដុល្លារអាមេរិក សមមូលនឹង ២៣៧,៥៥ លានអេសដេអ៊ែរ ស្មើនឹង ១៣,៩៧% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (១ ៧០០លានអេសដេអ៊ែរ) ដែលមានដូចខាងក្រោម៖
  - ដៃគូអភិវឌ្ឍន៍ពហុភាគី៖ បានចុះកិច្ចព្រមព្រៀងចំនួន ១ ដែលមានទឹកប្រាក់ប្រមាណចំនួន ៣៤,៨៧ លានដុល្លារអាមេរិក សមមូលនឹង ២៦,៤ លានអេសដេអ៊ែរ
  - ដៃគូអភិវឌ្ឍន៍ទ្វេភាគី៖ បានចុះកិច្ចព្រមព្រៀងចំនួន ៣ ដែលមានទឹកប្រាក់ប្រមាណចំនួន ២៧៨,៩១ លានដុល្លារអាមេរិក សមមូលនឹង ២១១,១៥ លានអេសដេអ៊ែរ
  - ការដកសាច់ប្រាក់ គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៤៖ បានដកសាច់ប្រាក់សរុបចំនួន ៤៩៤,៩០ លានដុល្លារអាមេរិក ឬ ប្រមាណ ២ ០១៧,១៣ លានរៀល ស្មើនឹង ២៨,៩៣% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន៖ហិរញ្ញប្បទានឥតសំណង៖ បានដកសាច់ប្រាក់សរុបចំនួនប្រមាណ ៣៨,៦៣ លានដុល្លារអាមេរិក ឬប្រមាណ ១៥៧,៧៧ ប៊ីលានរៀល ស្មើនឹង ២២,៦៦% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
  - ឥណទានសម្បទាន ៖ បានដកសាច់ប្រាក់សរុបចំនួនប្រមាណ ៤៥៦,២៧ លានដុល្លារអាមេរិក ឬ ប្រមាណ ១ ៨៥៩,៣៦ ប៊ីលានរៀល ស្មើនឹង ២៩,៦៣% នៃផែនការប្រចាំឆ្នាំ
  - បន្ទុកហិរញ្ញប្បទាន (វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស)៖ អនុវត្តបានចំនួន ៤៤០,៥០លានដុល្លារអាមេរិក ឬ ប្រមាណ ១ ៧៩៧,១៤ប៊ីលានរៀល ស្មើនឹង ២៨,៩៥% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

- ផលពិសេសផ្សេងៗទៀត ៖ ទទួលបានចំណូលពីការបង្វែរថវិកានៅសល់ក្នុងគណនីពង្រឹងសមត្ថភាពនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន ចំនួន ២៥៣ ៤១១,៤១ដុល្លារអាមេរិក សមមូលនឹង ១ ០២៥ ០៤៩ ១៥៣រៀល
- ការប្រមូលចំណូលពីការឱ្យប្រាក់កម្ចី (គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៤)៖ បានប្រមូលចំណូលសេវាបំណុលពីឥណទាយិកសរុបចំនួន ២៦៨,៦៩ ប៊ីលានរៀល ឬ ប្រមាណ៦៦,០២ លានដុល្លារអាម៉េរិកស្មើនឹង៤៧,១៦% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤
- សន្និធិបំណុល៖ តាមការប៉ាន់ស្មាន ដោយគិតបញ្ចូលទាំងបំណុលមរតកកំពុងចរចាដោះស្រាយ គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៤ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួនប្រមាណ ១១ ២១៩,៧៤ លានដុល្លារអាម៉េរិក ក្នុងនោះ បំណុលសាធារណៈក្រៅប្រទេស ដែលមានចំនួនប្រមាណ ១១ ១០៦,៥៣ លានដុល្លារអាម៉េរិក ត្រូវនឹងប្រមាណ៩៨,៩៩%នៃសន្និធិបំណុលសាធារណៈសរុប និងបំណុលសាធារណៈក្នុងប្រទេស មានចំនួនប្រមាណ ១១៣,២១ លានដុល្លារអាម៉េរិក ត្រូវនឹងប្រមាណ ១,០១% នៃសន្និធិ-បំណុលសាធារណៈសរុប។

➢ **ការគ្រប់គ្រងចំណាយសាធារណៈថ្នាក់ក្រោមជាតិ**
- បានដាក់ឱ្យអនុវត្តសារាចរណែនាំស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- បានចុះផ្សព្វផ្សាយសារាចរណែនាំរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២៥-២០២៧ និងនីតិវិធីរៀបចំគម្រោងថវិកាឆ្នាំ២០២៥
- បានដាក់ឲ្យអនុវត្តក្របខណ្ឌថវិការយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានបន្តបោះផ្សាយអាណត្តិឧបត្ថម្ភតុល្យភាពថវិកាជាតិ ជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ សម្រាប់ត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ២០២៤
- បានដាក់ឲ្យអនុវត្តសារាចរណែនាំស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

### ២.២.៣. ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

➢ គម្រោងចំណតរថយន្តឆ្លាតវៃ ក្រុងព្រះសីហនុ៖
- បានរៀបចំលិខិតសុំកិច្ចសហការជួបពិភាក្សាជាមួយក្រុមហ៊ុនទីប្រឹក្សា CRISIL Limited ដើម្បីប្រមូលទិន្នន័យជាធាតុចូលលើការសិក្សាសមិទ្ធិលទ្ធភាពពេញលេញ សម្រាប់គម្រោងចំណតឆ្លាតវៃក្រុងព្រះសីហនុ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានរៀបចំរបាយការណ៍ស្តីពីលទ្ធផលប្រជុំបូកសរុប នៃការបំពេញបេសកកម្មរបស់ក្រុមហ៊ុនទីប្រឹក្សាប្រតិបត្តការសម្រាប់រៀបចំការសិក្សាសមិទ្ធិលទ្ធភាពគម្រោងចំណតឆ្លាតវៃក្រុងព្រះសីហនុ
- បានរៀបចំតារាងមតិយោបល់លើរបាយការណ៍ចាប់ផ្តើមសម្រាប់សេវាប្រឹក្សាប្រតិបត្តិការសម្រាប់គម្រោងចំណតឆ្លាតវៃ ក្រុងព្រះសីហន

➢ គម្រោងមជ្ឈមណ្ឌលភស្តុភារកម្មភ្នំពេញ (PP-LC)៖ បានរៀបចំលក្ខខណ្ឌការងារស្នើសុំនៃវិធានការគាំទ្ររបស់រដ្ឋាភិបាលសម្រាប់គម្រោង Phnom Penh Logistic Complex (PP-LC)

➢ គម្រោងផ្លូវនាវាចរណ៍ "ព្រែកជីកហ្វូណនតេជោ" ៖
- បានរៀបចំលិខិតលើការស្នើយោបល់គោរពជូន សម្តេចធិបតី នាយករដ្ឋមន្ត្រី ពិនិត្យ និងពិចារណាលើកវិធានការបន្ទាប់ សម្រាប់ពន្លឿននីតិវិធីរៀបចំអភិវឌ្ឍគម្រោងព្រែកជីកហ្វូណនតេជោ
- បានរៀបចំកំណត់បង្ហាញជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ លើការស្នើសុំការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងក្របខណ្ឌសម្រាប់ដំណើរការ អនុវត្តគម្រោងផ្លូវនាវាចរណ៍ "ព្រែក-ជីកហ្វូណនតេជោ"

➢ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងអគ្គិសនី (E-bus) នៅក្រុងសៀមរាប៖
- បានរៀបចំរបាយការណ៍លទ្ធផលសិក្ខាសាលាដំបូងគោរពជូន ឯកឧត្តមរដ្ឋលេខាធិការ ស្តីពីការសិក្សាសមិទ្ធិលទ្ធភាពលើគម្រោងប្រព័ន្ធដឹកជញ្ជូនសាធារណៈ តាមរថយន្តក្រុងអគ្គិសនី នៅក្រុងសៀមរាប

- បានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ សម្រាប់ការរៀបចំប្រព័ន្ធដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងអគ្គិសនីនៅក្រុងសៀមរាបតាមយន្តការ PPP

➢ គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿនតភ្ជាប់ពីរាជធានីភ្នំពេញ-ខេត្តសៀមរាប-ក្រុងប៉ោយប៉ែតៈ បានរៀបចំលិខិតគោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស្តីពីករណីការស្នើសុំចុះហត្ថលេខាលើ កិច្ចព្រមព្រៀងស្តីពី វិសោធនកម្មកិច្ចព្រមព្រៀងក្របខណ្ឌ សម្រាប់ដំណើរការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿនតភ្ជាប់ពីរាជធានីភ្នំពេញ-ខេត្តសៀមរាប-ក្រុងប៉ោយប៉ែត

➢ គម្រោងមជ្ឈមណ្ឌលស្រាវជ្រាវត្រួតពិនិត្យឧបករណ៍បង្ការពន្លត់អគ្គិភ័យ និងគម្រោងបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈបង្ការ និងពន្លត់អគ្គិភ័យៈ បាននឹងកំពុងសិក្សាអំពីបទពិសោធន៍ប្រទេសនានា ស្តីពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនទាក់ទិនទៅនឹងវិស័យបង្ការ និងពន្លត់អគ្គិភ័យ

➢ កំណែទម្រង់គោលនយោបាយស្តីពី "ការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ"៖ បាននឹងកំពុងរង់ចាំកាលបរិច្ឆេទថ្មីសម្រាប់កិច្ចប្រជុំជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិភាក្សាលើការកែសម្រួលអនុក្រឹត្យស្តីពី "ការលើកទឹកចិត្ត និងការបង្កើត កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ"

➢ គម្រោងភូមិកីឡដ្ឋានៈ
- បានរៀបចំរបាយការណ៍សង្ខេបពីវឌ្ឍនភាព នៃគម្រោងអភិវឌ្ឍន៍ភូមិកីឡដ្ឋាន
- បានរៀបចំកំណត់បង្ហាញ និងចុះពិនិត្យប្រគល់ទទួលបញ្ចប់សុពលភាពគុណភាពសំណង់ "គម្រោង តភ្ជាប់បណ្តាញមេអគ្គិសនីទៅដល់ទីតាំងបុរីស្នាក់នៅរបស់កីឡាករ គ្រូបង្វឹក និងអាជ្ញាកណ្តាល សម្រាប់ព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ ឆ្នាំ២០២៣

➢ ការងារវិស័យអាទិភាពសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជនៈ បានរៀបចំរបាយការណ៍គោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ស្តីពី "ការសិក្សាបឋមពីការកំណត់វិស័យអាទិភាពសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន (២០២៥-២០៣៥)"។

## ២.៣. ការផ្តល់សេវាគាំទ្រទូទៅ និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ចំណុច២.៣.១ ត្រូវបានអនុវត្ត និងទទួលខុសត្រូវ ដោយអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។ អគ្គលេខាធិការដ្ឋាន មានបេសកកម្មសំខាន់ៗលើ ១.ការផ្តល់សេវាគាំទ្រសម្រាប់ប្រក្រតីភាពនៃដំណើរការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២. សម្របសម្រួលការងាររវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទក្រសួង ពិសេសមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត ៣. ជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ការបណ្តុះបណ្តាលនិងវិក្រឹត្យការ ព័ត៌មានវិទ្យាបណ្ណសារ[8]។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍បេសកកម្ម សំខាន់លើការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា[9]។ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារសំខាន់លើការបណ្តុះបណ្តាល និងវិក្រឹត្យការសមត្ថភាពមន្ត្រីរាជការលើមុខជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[10]។ ចំណែក ២.៣.២. ត្រូវបានអនុវត្ត និងទទួលខុសត្រូវដោយ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលមានបេសកកម្មសំខាន់លើការងារពង្រឹងប្រព័ន្ធគ្រប់គ្រងសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាំមុខក្នុងការអភិវឌ្ឍមុខងារសវកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ[11]។ ដោយឡែក ចំណុច ២.៣.៣. មានបេសកកម្មសំខាន់លើការងារធ្វើអធិការកិច្ច លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើអភិក្រម អធិការកិច្ចផ្អែកលើហានិភ័យ និងអធិការកិច្ចផ្អែកលើករណីសង្ស័យឬបណ្តឹងតវ៉ាជាក់ស្តែង[12]។ ចុងក្រោយ លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានមុខងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិត

---

[8] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[9] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[10] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[11] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[12] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បទដ្ឋានគតិយុត្ត ដើម្បីធានាសុវត្ថិភាពនីត្យានុកូលភាព នៃការគ្រប់គ្រងនិងការអភិវឌ្ឍ ប្រកបដោយសង្គតិភាព និងចីរភាព នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ជាលទ្ធផលប្រចាំឆមាសទី១ ឆ្នាំ២០២៤ អង្គភាពនីមួយៗ បានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម ៖

### ២.៣.១. ការផ្តល់សេវាគាំទ្រទូទៅ

- ជួបជាមួយតំណាងរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីពិភាក្សាលើលទ្ធភាពបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាលវគ្គខ្លីដល់មន្ត្រីរាជការ រដ្ឋបាលរាជធានីភ្នំពេញ
- បានចូលរួមកិច្ចប្រជុំសំណើចំនួន២ របស់ក្រសួងបរិស្ថាន រួមមាន អនុក្រឹត្យស្តីពីការកែសម្រួលស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានផ្តល់មតិប្រឹក្សាច្បាប់៖
    - លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការពង្រីកវិសាលភាពរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ
    - លើសេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃគណនីត្រូវសង
    - មតិប្រឹក្សាច្បាប់លើសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងតួនាទី ភារកិច្ច សិទ្ធអំណាច និងការទទួលខុសត្រូវរបស់អង្គភាពត្រួតពិនិត្យថវិកានៅអមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល



កម្រងសម្រង់បទប្បញ្ញត្តិច្បាប់សំខាន់ៗទាក់ទងសមត្ថកិច្ច
របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- រៀបចំនិងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីតិកម្ម និងប្រព័ន្ធទិន្នន័យច្បាប់៖
    - សម្រាប់កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធគយនិងរដ្ឋាករកម្ពុជា
    - សម្រាប់កម្រងសម្រង់បញ្ជីរាយនាមលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗ ពាក់ព័ន្ធកូវីដ-១៩
    - សម្រាប់កម្រងសម្រង់បទប្បញ្ញត្តិច្បាប់សំខាន់ៗ ទាក់ទងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមការងារបានចូលរួមកិច្ចប្រជុំពិភាក្សាលើការអនុវត្តការងារដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាមសំណល់រឹង និងផ្លាស្ទិកនៅកម្ពុជា ស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប
- ក្រុមការងារគណៈកម្មការអន្តរក្រសួងបានប្រជុំ kick Off Meeting ជាមួយអនុគណៈកម្មការខេត្ត កំពង់ធំ នៃអនុគម្រោងអូរអេតនៃគម្រោងកម្មវិធីការគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរកសិកម្មនៅកម្ពុជា ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ
- ក្រុមការងារបានចុះអង្កេតវាស់វែងលម្អិតលើទ្រព្យសម្បត្តិនានា របស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារអនុគម្រោងក្រពើ និងម្កាក់ ស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប អនុគម្រោងម៉ីនរាជ ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ, បានចុះកិច្ចសន្យាជាប្រជា-ពលរដ្ឋនៅអនុគម្រោងបណ្តុំព្រែក ស្ថិតក្នុងភូមិសាស្ត្រខេត្តកណ្តាល និងអនុគម្រោងកង្ហត ប្លុក C+D ស្ថិតក្នុងភូមិសាស្ត្រខេត្តបាត់ដំបង នៃគម្រោងកម្មវិធីការគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរកសិកម្មនៅកម្ពុជា
- ក្រុមការងារបានចុះធ្វើកិច្ចសន្យាជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ក្នុងភូមិសាស្ត្រខណ្ឌកំបូល និងខណ្ឌពោធិ៍សែនជ័យ (ផ្លូវរថភ្លើង) នៃគម្រោងផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូ និងប្រព័ន្ធរំដោះទឹក សម្រាប់បញ្ចៀសការជន់លិចនៅភូមិសាស្ត្ររាជធានីភ្នំពេញ

- ក្រុមការងារបានចុះធ្វើកិច្ចសន្យាជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់នៃគម្រោងប្រឡាយ៥៩ ក្នុងភូមិសាស្ត្រស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាលនៃគម្រោងផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូ និងប្រព័ន្ធរំដោះទឹក សម្រាប់បញ្ចៀសការជន់លិចនៅភូមិសាស្ត្ររាជធានីភ្នំពេញ
- ក្រុមការងារបានចុះបើកប្រាក់ឧបត្ថម្ភគោលនយោបាយជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់នៃគម្រោង៖
  - គម្រោងសាងសង់ស្ពានក្រចេះ និងផ្លូវតភ្ជាប់
  - គម្រោងប្រព័ន្ធធារាសាស្ត្រ និងកាត់បន្ថយទឹកជំនន់ខេត្តបន្ទាយមានជ័យ អនុគម្រោងអាងវាំងហែង និងកន្សែង
  - គម្រោងលើកកម្រិតផ្លូវជាតិលេខ ៧
  - គម្រោងប្រព័ន្ធស្រោចស្រព និងការពារទឹកជំនន់ស្ទឹងព្រែកត្នោត
  - ការសាងសង់ស្ថានីយថ្លឹងយានយន្តលើសទម្ងន់ ចំនួន២កន្លែង នៃគម្រោងស្ដារឡើងវិញកំណាត់ផ្លូវជាតិលេខ៥
  - អនុគម្រោងកង្កួតប្លុក C+D ស្ថិតក្នុងភូមិសាស្ត្រខេត្តបាត់ដំបង នៃគម្រោងកម្មវិធីការគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្ដូរកសិកម្មនៅកម្ពុជា
  - គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវ៉ៃកូ ជំហាន២ ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រៃវែង
  - គម្រោងសាងសង់ស្ពានឆ្លងកាត់ទន្លេបាសាក់
  - អនុគម្រោងប្រព័ន្ធលូបង្ហូរទឹកកខ្វក់ គម្រោងកែលម្អ គ្រប់គ្រងបរិស្ថានក្រុងជុំវិញបឹងទន្លេសាបជំហាន២
  - អនុគម្រោងកែលម្អផ្លូវជនបទខេត្តកំពតជំហាន៣ នៃគម្រោងខ្សែច្រវាក់ផលិតកម្មប្រកបដោយភាតរៈបរិស្ថាន
- ក្រុមការងារបានចុះត្រួតពិនិត្យលើដំណើរការចុះកិច្ចសន្យា និងការបើកប្រាក់សំណងគោលនយោបាយជូនប្រជាពលរដ្ឋរងផលប៉ះពាល់នៃគម្រោង៖
  - គម្រោងធារាសាស្ត្រ និងកាត់បន្ថយទឹកជំនន់ខេត្តបន្ទាយមានជ័យ
  - គម្រោងស្ដារឡើងវិញកំណាត់ផ្លូវជាតិលេខ៥
  - គម្រោងកែលម្អ និងស្ដារឡើងវិញប្រព័ន្ធស្រោចស្រព និងប្រព័ន្ធរំដោះទឹកភាគនិរតីរាជធានីភ្នំពេញ
  - គម្រោងប្រព័ន្ធស្រោចស្រព និងការពារទឹកជំនន់ស្ទឹងព្រែកត្នោត
  - គម្រោងលើកកម្រិតផ្លូវជាតិលេខ៧
  - គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវ៉ៃកូជំហាន២
  - គម្រោងសាងសង់ និងលើកកម្រិតផ្លូវជាតិលេខ៣១
  - គម្រោងខ្សែច្រវាក់ផលិតកម្មប្រកបដោយភាតរៈបរិស្ថាន។

### ២.៣.២ ការងារសវនកម្មផ្ទៃក្នុង

- បានបញ្ជូនរបាយការណ៍សវនកម្ម និងលិខិតជំរុញនៅអគ្គនាយកដ្ឋានពន្ធដារឆ្នាំ២០២២ និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈឆ្នាំ២០២៣
- បានបញ្ចប់ការរៀបចំរបាយការណ៍សវនកម្មឆ្នាំ២០២៣ រួមមាន៖ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី ខេត្តកែប ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តកំពង់ចាម និងខេត្តក្រចេះ
- បានបញ្ចប់ការរៀបចំលិខិតជំរុញជុំទី៣ ទី៤ និងទី៥ ឆ្នាំ២០២៣ និងបានបញ្ជូនទៅអង្គភាពពាក់ព័ន្ធ
- បានបញ្ចប់ការចុះបេសកកម្មជាមួយជំនាញការ IMF ក្នុងការធ្វើសវនកម្មលើការគ្រប់គ្រងការអភិវឌ្ឍ និងប្រសិទ្ធភាពប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ និងអង្គភាពក្រោមឱវាទ និងបានបញ្ជូនកំណត់ហេតុកិច្ចប្រជុំឆ្លង និងឧបសម្ព័ន្ធទី១ ផែនការសកម្មភាពកែលម្អទៅ អពដ ដើម្បីពិនិត្យ មុននឹងចុះហត្ថលេខារួមគ្នា
- បន្តចុះធ្វើសវនកម្មឆ្នាំ២០២៣ នៅអគ្គលេខាធិការដ្ឋាននិងអង្គភាពលទ្ធកម្មនៃកសហវ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- បានបញ្ចប់ការចុះសវនកម្ម និងការរៀបចំរបាយការណ៍សវនកម្មឆ្នាំ២០២៤ រួមមានខេត្តកោះកុង ខេត្តត្បូងឃ្មុំ ខេត្តបន្ទាយមានជ័យ ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង

- បានចុះធ្វើសវនកម្មឆ្នាំ២០២៤ នៅខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តប៉ៃលិន ខេត្តមណ្ឌលគិរី និងខេត្តស្វាយរៀង និងកំពុងរៀបចំរបាយការណ៍
- បានចុះធ្វើសវនកម្ម និងបញ្ចប់ការរៀបចំរបាយការណ៍សវនកម្មស្តីពីការអនុវត្តនីតិវិធីលើការត្រួតពិនិត្យ និងអនុវត្តចំណាយថវិកាសម្រាប់ការជួសជុលកែលម្អអគារ និងទិញសម្ភារៈ បរិក្ខាររបស់មន្ទីរពេទ្យហ្លួងម៉ែ នៅអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- កំពុងចុះធ្វើសវនកម្មសមិទ្ធកម្មលើប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ
- កំពុងចុះធ្វើសវនកម្មឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយ
- បានបញ្ជូនរបាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច, តារាងតុល្យភាពគណនីរជ្ជទេយ្យបុរេប្រទាន, ទិន្នានុប្បវត្តិទូទៅសៀវភៅធំ,តារាងតាមដានស្ថានភាពរជ្ជទេយ្យបុរេប្រទានបញ្ជីបេឡាក្នុងដៃរបស់រជ្ជទេយ្យករ, បញ្ជីតាមដានប្រាក់របស់រជ្ជទេយ្យករនៅធនាគារ ប្រចាំខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២៣ ប្រចាំខែមករា ខែកុម្ភៈ ខែមីនា ខែមេសា ខែឧសភា ឆ្នាំ២០២៤ ទៅអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ
- បានបញ្ជូនរបាយការណ៍សវនកម្ម និងលិខិតជំរុញនៅអគ្គនាយក-ដ្ឋានពន្ធដារ ឆ្នាំ២០២២ និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈឆ្នាំ២០២៣
- បន្តចុះធ្វើសវនកម្មឆ្នាំ២០២៣ នៅអគ្គលេខាធិការដ្ឋាននិងអង្គភាពលទ្ធកម្មនៃកសហវ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- បានបញ្ចប់ការចុះសវនកម្ម និងការរៀបចំរបាយការណ៍សវនកម្មឆ្នាំ២០២៤ រួមមានខេត្តកោះកុង ខេត្តត្បូងឃ្មុំ ខេត្តបន្ទាយ-មានជ័យ ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង
- បានចុះធ្វើសវនកម្មឆ្នាំ២០២៤ នៅខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ ខេត្តប៉ៃលិន ខេត្តមណ្ឌលគិរី និងខេត្តស្វាយរៀង

### ២.៣.៣ ការងារអធិការកិច្ច

- បានបញ្ចូលទិន្នន័យថ្ងៃឈប់សំរាកទៅក្នុងប្រព័ន្ធ FIDS, និងកែសម្រួលមុខងារចំនួន៩ នៃប្រព័ន្ធ FIDS ស្របតាមតម្រូវការ និងបញ្ហាជាក់ស្តែង
- បានសិក្សាស្រាវជ្រាវលើទម្រង់បណ្តឹងរបស់ក្រសួង ស្ថាប័ន និងរៀបចំទម្រង់បណ្តឹងរបស់ អគ្គាធិការដ្ឋាន
- បានរៀបចំសេចក្តីព្រាងលេខកូដស្តង់ដារវិធានការសម្រាប់មុខងាររបាយការណ៍លទ្ធផលអធិការកិច្ចហិរញ្ញវត្ថុនៃប្រព័ន្ធ FIDS
- បានរៀបចំសេចក្តីព្រាងរបាយការណ៍បូកសរុបលទ្ធផលអធិការកិច្ចហិរញ្ញវត្ថុជំហានទី៣ របស់ក្រសួងផែនការ,សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល,ក្រសួងពាណិជ្ជកម្ម, ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, សាកលវិទ្យាល័យភូមិន្ទ-នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, វិទ្យាស្ថានសុខភាពសាធារណៈ និងក្រុមហ៊ុនហ្វ្រីនត្រេដ ការិយបរិច្ឆេទ២០២២
- បានធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុជំហានទី១ ឆ្នាំ២០២៤ របស់គណៈប្រតិភូបានធ្វើអធិការ-កិច្ចហិរញ្ញវត្ថុ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋការិយបរិច្ឆេទ២០២៣ នៅតាមបណ្តាមន្ទីរជំនាញក្នុងខេត្តតាកែវ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តមណ្ឌលគិរី
- បានបញ្ចប់ការចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២២ នោះ
    - ក្រសួង-ស្ថាប័ន៖ ក្រសួងផែនការ, ក្រសួងពាណិជ្ជកម្ម, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, និងក្រសួងយុត្តិធម៌ និងបណ្តាអង្គភាពថវិកាក្រោមចំណុះ
    - គ្រឹះស្ថានសាធារណៈរដ្ឋបាល៖ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, វិទ្យាស្ថានជាតិសុខភាពសាធារណៈ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច,ក្រុមហ៊ុន ហ្វ្រីនត្រេដ, វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្មកម្ពុជា, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល, សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ, ខេត្តបាត់ដំបង, ខេត្តព្រះសីហនុ,ខេត្តត្បូងឃ្មុំ,បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងមន្ទីរពេទ្យព្រះអង្គឌួង

- បានបញ្ចប់ការចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២៣ នៅ៖ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលឃុំ/សង្កាត់ សាលាដំបូង មន្ទីរជំនាញ និងអង្គភាពថវិកាពាក់ព័ន្ធក្រោមចំណុះក្នុងខេត្តសៀមរាប ខេត្តតាកែវ ខេត្តបាត់ដំបង និងខេត្តមណ្ឌលគិរី
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២៣ នៅ៖
    - ក្រសួង-ស្ថាប័ន៖ ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងធម្មការនិងសាសនា ក្រសួងអភិវឌ្ឍន៍-ជនបទ ក្រសួងបរិស្ថាន ក្រសួងព័ត៌មាន និងអង្គភាពក្រោមចំណុះ
    - គ្រឹះស្ថានសាធារណៈរដ្ឋបាល៖ បេឡាជាតិសន្តិសុខសង្គម មន្ទីរពេទ្យកាល់ម៉ែត
- បានបញ្ចប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២២ នៅ៖
    - ក្រសួង-ស្ថាប័ន៖ ក្រសួងកិច្ចការនារី, ក្រសួងព័ត៌មាន, ក្រសួងធម្មការ និងសាសនានិងបណ្ដាអង្គភាពថវិកាក្រោមចំណុះ
    - គ្រឹះស្ថានសាធារណៈរដ្ឋបាល៖ និយ័តករទូរគមនាគមន៍កម្ពុជា, មន្ទីរពិសោធន៍សំណង់សាធារណការ, វិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ, សាកលវិទ្យាល័យជាតិមានជ័យ, គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង, វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ, វិទ្យាស្ថានពហុ-បច្ចេកទេសភូមិភាគតេជោសែនសៀមរាប, អាជ្ញាធរជាតិអប្សរា និងគ្រឹះស្ថានអង្គរ
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២២ នៅ៖ ក្រសួង-ស្ថាប័ន៖ ទីស្ដីការគណៈរដ្ឋមន្ត្រី, ក្រសួងទេសចរណ៍, ក្រសួងមុខងារសាធារណៈ, ក្រសួងរ៉ែនិងថាមពល, ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបណ្ដាអង្គភាពថវិកាក្រោមចំណុះ
- បានបញ្ចប់ការចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២៣ នៅ៖ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលឃុំ/សង្កាត់ សាលាដំបូង មន្ទីរជំនាញនិងអង្គភាពថវិកាពាក់ព័ន្ធក្រោមចំណុះក្នុងខេត្តកោះកុង ខេត្តកំពត និងខេត្តរតនគិរី
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២៣ នៅ៖
    - ក្រសួង-ស្ថាប័ន៖ ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងធម្មការនិងសាសនា ក្រសួងអភិវឌ្ឍន៍-ជនបទ ក្រសួងបរិស្ថាន ក្រសួងព័ត៌មាន និងអង្គភាពក្រោមចំណុះ
    - គ្រឹះស្ថានសាធារណៈរដ្ឋបាល៖ បេឡាជាតិសន្តិសុខសង្គម មន្ទីរពេទ្យកាល់ម៉ែត
- បានបញ្ចប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២២ នៅ៖
    - ក្រសួង-ស្ថាប័ន៖ ក្រសួងកិច្ចការនារី, ក្រសួងព័ត៌មាន, ក្រសួងធម្មការ និងសាសនានិងបណ្ដាអង្គភាពថវិកាក្រោមចំណុះ
    - គ្រឹះស្ថានសាធារណៈរដ្ឋបាល៖ និយ័តករទូរគមនាគមន៍កម្ពុជា, មន្ទីរពិសោធន៍សំណង់សាធារណការ, វិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ, សាកលវិទ្យាល័យជាតិមានជ័យ, គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង, វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ, វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប, អាជ្ញាធរជាតិអប្សរា និងគ្រឹះស្ថានអង្គរ
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២២ នៅ៖ ក្រសួង-ស្ថាប័ន៖ ទីស្ដីការគណៈរដ្ឋមន្ត្រី, ក្រសួងទេសចរណ៍, ក្រសួងមុខងារសាធារណៈ, ក្រសួងរ៉ែនិងថាមពល ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបណ្ដាអង្គភាពថវិកាក្រោមចំណុះ

- បានបញ្ចប់ការចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២៣ នៅ៖ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលឃុំ/សង្កាត់ សាលាដំបូង មន្ទីរជំនាញនិងអង្គភាពថវិកាពាក់ព័ន្ធក្រោមចំណុះក្នុងខេត្តកោះកុង ខេត្តកំពត និងខេត្តរតនគិរី
- បានបញ្ចប់ការចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២២ នៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលឃុំ/សង្កាត់ សាលាដំបូង មន្ទីរជំនាញនិងអង្គភាពថវិកាពាក់ព័ន្ធ នៅខេត្តកែប
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់ការិយបរិច្ឆេទ២០២៣ នៅ៖
  - ក្រសួង-ស្ថាប័ន៖ក្រសួងទេសចរណ៍, ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា និងអង្គភាពក្រោមចំណុះ
  - គ្រឹះស្ថានសាធារណៈរដ្ឋបាល៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**៣.ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ដោយគ្រប់អង្គភាពទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទីចូលរួម អនុវត្ត លើកកម្ពស់ ក្នុងការងារកែទម្រង់-ហិរញ្ញវត្ថុសាធារណៈគ្រប់ដំណាក់កាល ដើម្បីឱ្យការងារគ្រប់គ្រងសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ ក្នុងក្រសួង ក៏ដូចជា គ្រប់ក្រសួងស្ថាប័ន កាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ដូចនេះ ផ្នែកទី៣ នេះ ត្រូវបានអនុវត្ត និងទទួលខុសត្រូវ ពីគ្រប់អង្គភាពទាំងអស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជាលទ្ធផល អង្គភាពបានអនុវត្តនិងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

- បានរៀបចំរបាយការណ៍កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើសេចក្តីព្រាងចុងក្រោយ នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០
- បានសហការរៀបចំកិច្ចប្រជុំអន្តរក្រសួងពិនិត្យនិងពិភាក្សាលើសេចក្តីព្រាង "សារាចរណែនាំស្តីពីការអនុវត្តគោលការណ៍និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ជូនក្រសួងស្ថាប័ន និងមន្ទីរជំនាញក្រោមឱវាទសម្រាប់ដំណាក់កាលទី៣
- បានរៀបចំលិខិតស្នើសុំផ្តល់កិច្ចសន្យា ឬ សៀវភៅបន្ទុក និងឯកសារពាក់ព័ន្ធនឹងចំណូល ពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលផ្សេងៗសម្រាប់រៀបចំទិន្នន័យមេនៅក្នុងប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងស្នើសុំផ្តល់ឈ្មោះអ្នកប្រើប្រាស់ប្រព័ន្ធ (NRMIS-Users) របស់ក្រសួង ស្ថាប័ន ចំនួន១៦ ដែលនៅ សេសសល់ និងមន្ទីរ អង្គភាពជំនាញក្រោមឱវាទ
- បានរៀបចំ កិច្ចពិភាក្សាលើការរៀបចំសេចក្តីព្រាងសារាចរ និងសេចក្តីជូនដំណឹងស្តីពីការដាក់ឱ្យប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី៣ និងការរៀបចំអភិវឌ្ឍប្រព័ន្ធ NRMIS Version2
- បានរៀបចំកិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពនៃការរៀបចំនីតិវិធីអនុវត្តចំណូលបង្គរ និងចំណូលពន្យារនៅក្នុងប្រព័ន្ធ NRMIS និង ប្រព័ន្ធ FMIS
- បានសហការប្រជុំពិនិត្យលើវឌ្ឍនភាពនៃ ការកែសម្រួលលក្ខខណ្ឌនៃការអនុវត្តចំណូលបង្គរ និងចំណូលពន្យារនៅក្នុងប្រព័ន្ធ NRMIS
- បានរៀបចំលេខកូដចំណូល និងបញ្ជីឈ្មោះអ្នកប្រើប្រាស់ របស់ក្រសួង ស្ថាប័ន ដែលនៅសេសសល់ទាំង ១៦ ដើម្បីប្រមូលជាតុចូលបន្ថែមក្នុងការពិនិត្យ និងកែសម្រួលប្រព័ន្ធ NRMIS
- បានរៀបចំ និងកិច្ចសហការ ដើម្បីពិនិត្យ និងពិភាក្សា លើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី ១ ឆ្នាំ ២០២៤
- បានចូលរួមកិច្ចប្រជុំជាមួយជំនាញការអន្តរជាតិរបស់អង្គការយូនីសេហ្វ លើការវាយតម្លៃថ្នាក់តំបន់លើការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពាក់ព័ន្ធការគ្រប់គ្រងហានិភ័យសម្រាប់ការការពារសង្គមឆ្លើយតបនឹងវិបត្តិនៅក្នុង

តំបន់អាស៊ីអាគ្នេយ៍ ដែលរៀបចំដោយអង្គការយូនីសេហ្វ មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ

- បានចូលរួមប្រជុំពិនិត្យ និងពិភាក្សាប្រចាំសប្តាហ៍ និងប្រចាំខែ ឬ តាមពេលវេលាជាក់ស្តែងដែលរៀបចំដោយក្រុមការងារអភិវឌ្ឍន៍ប្រព័ន្ធ SARMIS ក្នុងគោលបំណងផ្តល់ និងប្រមូលធាតុចូលបន្ថែមលើការអភិវឌ្ឍន៍ប្រព័ន្ធ SARMIS Ver.2 ឱ្យស្របតាមតម្រូវការងារបច្ចុប្បន្ន និងពេលវេលា
- បានរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ប្រចាំត្រីមាសទី២ ឆ្នាំ២០២៤
- បានពិនិត្យ និងផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងបរិស្ថាន
- បានសហការរៀបចំកិច្ចប្រជុំយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល
- បានសហការ រៀបចំលើទស្សនាទានសិក្សាស្តីពីការសិក្សាលើការផ្តល់សេវាសាធារណៈក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស TWG ដើម្បីពិនិត្យ និងពិភាក្សា លើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៤
- បានសហការផ្តល់ព័ត៌មានអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងស្ថាប័នចំនួន ៥ ដើម្បី សម្របសម្រួលជំរុញការរៀបចំនិងអនុវត្តសកម្មភាពកែទម្រង់តាមយន្តការក្រុមការងារកែទម្រង់
- បានពិនិត្យ និងពិភាក្សាលើសេចក្តីព្រាង "សារាចរណែនាំស្តីពីការអនុវត្តគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ"
- សិក្ខាសាលាស្តីពី "ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) ឆ្នាំ ២០២៥-២០២៧ និងផែនការបន្ទាប់សម្រាប់ត្រៀមរៀបចំក្របខ័ណ្ឌ MTFF ឆ្នាំ ២០២៦-២០២៨" ។

# សេចក្តីសន្និដ្ឋាន

យោងតាមខ្លឹមសារដូចដែលបានពណ៌នាក្នុងរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំឆមាសទី១ ឆ្នាំ២០២៤ នេះ ពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញពីការបំពេញតួនាទីយ៉ាងសកម្មពី គ្រប់អង្គភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងការងារប្រចាំថ្ងៃ និងការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្នុង នាមជាសេនាធិការរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅកម្ពុជា។ ទន្ទឹមគ្នានេះ របាយការណ៍នេះ ក៏បានសបញ្ជាក់ពីបទពិសោធន៍ល្អៗ ចំណុចខ្លាំង និងចំណុចមួយចំនួនតូច ដែល នៅមានការខ្វះខាតក្នុងការអនុវត្តការងាររបស់អង្គភាពនីមួយៗ ដែលនេះអាចជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់ ជាមូលដ្ឋានធ្វើការពិនិត្យ តាមដាន វាយតម្លៃ និងកែលម្អ គុណភាពការងារឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគុណភាព ដើម្បីជាកាតាលីករជំរុញគាំទ្រដល់កត្តាកំណត់ភាពជោគជ័យ លើការអនុវត្តការងាររបស់ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាចីរកាលតរៀងទៅ។ តាមរយៈនេះ យើងអាចវាយតម្លៃបានថា យន្តការរៀបចំរបាយ-ការណ៍ស្តីពីសកម្មភាពការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានមកពីការបូកសរុបរបាយការណ៍សកម្មភាព ការងារនៃគ្រប់អង្គភាពក្រោមឱវាទក្រសួង ពិតជាមានអត្ថប្រយោជន៍ និងគុណតម្លៃខ្ពស់ដែលប្រៀបដូចជាការ ត្រួតពិនិត្យតាមដានការអនុវត្តការងារដោយផ្អែកលើសមិទ្ធផលជាក់ស្តែងរបស់អង្គភាពនីមួយៗ និងថែមទាំង បានជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលដល់ស្មារតី នៃការអនុវត្តការងាររបស់ថ្នាក់ដឹកនាំ និងបុគ្គលិកមន្ត្រី-រាជការ នៃគ្រប់អង្គភាពឱ្យកាន់តែខិតខំប្តេជ្ញាចិត្តបំពេញកិច្ចការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាង ខ្ជាប់ខ្ជួនថែមមួយកម្រិតទៀត ហើយវាពិតជាមានសារសំខាន់ណាស់ដែលក្រសួងត្រូវតែបន្តអនុវត្តយន្តការនេះ ឱ្យបានជាប់ជាប្រចាំ ព្រមទាំងជំរុញកិច្ចការនេះឱ្យកាន់តែមានគុណភាព ប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយបន្ថែម ទៀត។

ទោះស្ថិតក្នុងស្ថានភាពនៃការប៉ះពាល់ដោយសារសង្គ្រាមរវាងប្រទេសរូស្ស៊ី និងប្រទេសអ៊ុយក្រែន និងជំងឺ កូវីដ-១៩ ក៏ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងនៅតែប្រកាន់គោលជំហរខិតខំប្រឹងប្រែងប្រកបដោយផែនការ និង យន្តការច្បាស់លាស់ ក្នុងភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ចំពោះការបំពេញមុខងារភារកិច្ចរបស់ខ្លួន ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការធានាចីរភាព នៃកំណើនសេដ្ឋកិច្ចនិងអភិវឌ្ឍវិស័យ ហិរញ្ញវត្ថុនៅកម្ពុជា ឱ្យកាន់តែមានវឌ្ឍនភាពរីកចម្រើនទៅមុខជាលំដាប់។ ទន្ទឹមគ្នានេះ ដើម្បីឈានទៅរកការ សម្រេចជោគជ័យស្របតាមគោលបំណងគោលនយោបាយរបស់ក្រសួង វាពិតជាចាំបាច់ណាស់ដែលទាមទារ ឱ្យមានការចូលរួមចំណែកពីគ្រប់អង្គភាពទាំងអស់ក្រោមឱវាទក្រសួង ព្រមទាំងបន្តខិតខំបង្កើនប្រសិទ្ធភាព ការងារបន្ថែមទៀត ដោយឈរលើគោលការណ៍តម្កល់ប្រយោជន៍រួមជាធំ ដើម្បីសម្រេចបានសមិទ្ធផលតាមសូច-នាករដែលបានគ្រោងទុក ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់ទិសដៅសំខាន់ជាយុទ្ធសាស្ត្រ ក្នុងការ អភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតិ ទាំងក្នុងតួនាទីជានិម្មាបនករ និងជាប្រតិបត្តិករ ស្របតាមយុទ្ធសាស្ត្រចតុ-កោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា និងស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នីតិកាលទី៧ នៃរដ្ឋសភា។